CCB_NRBM_15

# របាយការណ៍វគ្គបណ្តុះបណ្តាល ស្តីពី

## ទស្សនះទាន និងវិធីសាស្ត្ររៀបចំសហគមន៍ទេសចរណ៍ធម្មជាតិ

ទំបក់ ថ្ងៃទី 21-25 ខែសីហា 2006



គាំទ្រដោយ :

ថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០០៦

library.ncdd.gov.kh
006221

បណ្ណាល័យ
គ.ជ.អ.ប

# មាតិកា

| | |
|---|---|
| | ទំព័រ |
| ១. សេចក្តីផ្តើម និង កម្មវិធីវគ្គបណ្តុះបណ្តាល | ១-៣ |
| ២. កំណត់ត្រាថ្ងៃទី១ : ថ្ងៃច័ន្ទ ទី២១ ខែសីហា ឆ្នាំ២០០៦ | ៤-៦ |
| ៣. កំណត់ត្រាថ្ងៃទី២ : ថ្ងៃអង្គារ៍ ទី២២ ខែសីហា ឆ្នាំ២០០៦ | ៧ |
| ៤. កំណត់ត្រាថ្ងៃទី៣ : ថ្ងៃពុធ ទី២៣ ខែសីហា ឆ្នាំ២០០៦ | ៨ |
| ៥. កំណត់ត្រាថ្ងៃទី៤ : ថ្ងៃព្រហស្បត្តិ ទី២៤ ខែសីហា ឆ្នាំ២០០៦ | ៩-២១ |
| ៦. កំណត់ត្រាថ្ងៃទី៥ : ថ្ងៃសុក្រ ទី២៥ ខែសីហា ឆ្នាំ២០០៦ | ២២-៣៣ |

បញ្ជីឧបសម្ព័ន្ធ :

- ឯកសារចែក ទី១ : មូលដ្ឋានគ្រឹះនៃទេសចរណ៍
- ឯកសារចែក ទី២ : ទេសចរណ៍ជាប្រព័ន្ធមួយ (ប្រព័ន្ធទេសចរណ៍)
- ឯកសារចែក ទី៣ : សហគមន៍ទេសចរណ៍-គោលការណ៍ បញ្ហា និងដំណើរការ
- ឯកសារចែក ទី៤ : ការជ្រើសរើសតំបន់សំរាប់សហគមន៍ទេសចរណ៍
- ឯកសារចែក ទី៥ : ការសិក្សាអំពីលទ្ធភាពអាចធ្វើបាន
- ឯកសារចែក ទី៦ : ការសិក្សាទីផ្សារទេសចរណ៍សហគមន៍
- ឯកសារចែក ទី៧ : ការត្រួតពិនិត្យ និងវាយតំលៃ
- ឯកសារចែក ទី៨ : ការចូលរួម និងបណ្តាញ

333.72
REP
sh: Natural Res



## សេចក្តីផ្តើម

សហគមន៍ទេសចរណ៍ធម្មជាតិ គឺជាវិធីសាស្ត្រចូលរួមគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថានមួយបែប ដែលកំពុងរីកលូតលាស់ច្រើនឡើងស្ទើរគ្រប់ខេត្ត-ក្រុងនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។ ការរៀបចំសហគមន៍ទេសចរណ៍ធម្មជាតិ ជួយអោយសហគមន៍ចូលរួមសកម្មនៅក្នុងការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន ដែលពួកគេពឹងផ្អែក ដែលកំពុងទទួលរងនូវការបាត់បង់ខូចខាត ។ ការគ្រប់គ្រងបែបនេះ ផ្តល់ដល់សហគមន៍នូវការងារ និងប្រាក់ចំណូល ធ្វើអោយប្រសើរឡើងវិញនូវធនធានធម្មជាតិ ព្រមទាំងធានានូវសាមគ្គីភាពសហគមន៍ និងវប្បធម៌សង្គមល្អទៀតផង ។

ជាទូទៅ អ្នកសំរបសំរួលនៅថ្នាក់ខេត្ត ក្រុងនៃកម្មវិធីសិលា និងសមាជិករបស់CCBEN មានការយល់ដឹង និងបទពិសោធន៍តិចតួចលើដំណើរការរៀបចំបង្កើតសហគមន៍ទេសចរណ៍ធម្មជាតិ ។ ពួកគេប្រើប្រាស់បទពិសោធន៍ពីការរៀបចំសហគមន៍ព្រៃឈើ ឬសហគមន៍នេសាទ ដើម្បីជួយសហគមន៍រៀបចំសហគមន៍ទេសចរណ៍ធម្មជាតិនេះ។ ដើម្បីអាចជួយអោយដំណើររៀបចំនេះ ប្រព្រឹត្តទៅបានល្អប្រសើរ និងមានប្រសិទ្ធភាព អ្នកសំរបសំរួលទាំងនោះត្រូវការការបណ្តុះបណ្តាល ស្តីពីទស្សនៈទាន វិធីសាស្ត្រ និងឧបករណ៍នានាប្រើប្រាស់នៅក្នុងដំណើរការរៀបចំសហគមន៍ទេសចរណ៍ធម្មជាតិ ។

ដោយមានការសំរបសំរួលពីគំរោងគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន នៃកម្មវិធីសិលាថ្នាក់ជាតិ ព្រមទាំងមានការសហការ និងការគាំទ្រពីអង្គការCCBEN និងសកលវិទ្យាល័យភូមិន្ទភ្នំពេញ វគ្គបណ្តុះបណ្តាលស្តីពីទស្សនៈទាន និងវិធីសាស្ត្ររៀបចំសហគមន៍ទេសចរណ៍ធម្មជាតិ ត្រូវបានរៀបចំឡើងរយៈពេល៥ថ្ងៃ ចាប់ពីថ្ងៃទី២១ ដល់ថ្ងៃទី២៥ ខែសីហា ឆ្នាំ២០០៦ នៅសកលវិទ្យាល័យភូមិន្ទភ្នំពេញ និងរមណីដ្ឋានទឹកធ្លាក់ចំបក់ ខេត្តកំពង់ស្ពឺ ។

## គោលបំណង

ក្រោយវគ្គបណ្តុះបណ្តាលចប់ អ្នកចូលរួម នឹងអាច :

- យល់ដឹងពីគោលគំនិតជាមូលដ្ឋានអំពីទេសចរណ៍ធម្មជាតិ : និយមន័យ ប្រភេទ ប្រព័ន្ធ និងឥទ្ធិពល...
- យល់អំពីគោលការណ៍សហគមន៍ទេសចរណ៍ធម្មជាតិ អត្ថន័យ និងបញ្ហា...
- កំណត់ស្ថានភាពមួយ/សហគមន៍មួយសំរាប់គាំទ្រការរៀបចំសហគមន៍ទេសចរណ៍ធម្មជាតិ...
- រៀបចំផែនការសំរាប់ការគ្រប់គ្រងសហគមន៍ទេសចរណ៍ធម្មជាតិ
- យល់ដឹងអំពីអ្នកពាក់ព័ន្ធនៅក្នុងវិស័យទេសចរណ៍ ហើយអាចកសាងទាំងបណ្តាញផ្លូវការ និងមិនផ្លូវការ...
- តាមដាន និងវាយតំលៃគំរោងសហគមន៍គ្រប់គ្រងទេសចរណ៍ធម្មជាតិ...

## វិធីសាស្ត្រ

វគ្គបណ្តុះបណ្តាលនេះ ត្រូវបានរៀបចំឡើងមានរយៈពេល៥ថ្ងៃ ចាប់ពីថ្ងៃទី២១ ដល់២៥ ខែសីហា ឆ្នាំ២០០៦ ដែលមានអ្នកចូលរួមសរុប៣០នាក់ (សូមមើលឧបសម្ព័ន្ធ : បញ្ជីវត្តមាន) មកពីខេត្ត-ក្រុងគោលដៅNREM ចំនួន ១០ខេត្ត-ក្រុង និងសមាជិករបស់CCBEN ។ ផ្អែកលើគោលបំណងនៃវគ្គបណ្តុះបណ្តាល វិធីសាស្ត្របែបចូលរួមត្រូវបាន អនុវត្តនៅក្នុងដំណើរការវគ្គនេះ ដូចជា ការបង្ហាញ និងចែករំលែកបទពិសោធន៍ ការបំផុសគំនិត ក្រុមពិភាក្សា ការរៀន ពីពីករណីសិក្សា ការសំដែង និងការ ចុះអនុវត្ត ជាក់ស្តែងនៅតាមភូមិ ព្រមទាំងការធ្វើលំហាត់នៅផ្ទះ ជាដើម ។ល។

## សិក្ខាកាមចូលរួម :

សិក្ខាកាមចូលរួមសរុបមានចំនួន ៣០នាក់ មានរាយដូចខាងក្រោម :

1. មន្ត្រីបង្គោល NREMថ្នាក់ខេត្ត ក្រុង 1x10
2. ទីប្រឹក្សាបច្ចេកទេស NREMខេត្ត ក្រុង 1x10
3. មន្ទីរទេសចរ/បរិស្ថាន ខេត្ត ក្រុង (អនុវត្ត PIF) 1x5
4. សមាជិក CCBEN 1x5

## ទីកន្លែង :

- ទ្រឹស្តី : សកលវិទ្យាល័យភូមិន្ទភ្នំពេញ (២១-២២ សីហា ២០០៦)
- ទ្រឹស្តី និងការអនុវត្ត : រមណីដ្ឋានទឹកធ្លាក់ចំបក់ ខេត្តកំពង់ស្ពឺ (២៣-២៥ សីហា ២០០៦)

## កម្មវិធីវគ្គបណ្តុះបណ្តាល

| ពេលវេលា | សកម្មភាព | អ្នកទទួលខុសត្រូវ |
|---|---|---|
| **ថ្ងៃទី១ : ថ្ងៃច័ន្ទ ទី២១ ខែសីហា ឆ្នាំ២០០៦** | | |
| 07:30 – 08:00 | ការចុះបញ្ជីអ្នកចូលរួម | លោក ហាក់ សុខលាភ |
| 08:00 – 08:15 | មតិស្វាគមន៍បើកវគ្គបណ្តុះបណ្តាល | លោក សួស ពិនរក្ស |
| 08:15 – 09:00 | ការណែនាំខ្លួន ការរំពឹងទុក និងបទបញ្ជាផ្ទៃក្នុង | លោក ម៉ែន ប្រាជ្ញវុទ្ធី |
| 09:00– 10:00 | គោលគំនិតជាមូលដ្ឋាន ស្តីពីទេសចរណ៍ : និយមន័យ ប្រភេទអ្នកទេសចរពិភពលោក និងនៅប្រទេសកម្ពុជា | អ្នកស្រី វិទ្ធិ សំអុល |
| 10:00 – 10:15 | សំរាកអាហារស្រាល | |
| 10:15 – 12:00 | ឥទ្ធិពលទេសចរណ៍ | អ្នកស្រី វិទ្ធិ សំអុល |
| 12.00 – 14.00 | សំរាកបាយថ្ងៃត្រង់ | |

| | | |
|---|---|---|
| 14:00 – 15:30 | អេកូទេសចរណ៍ | អ្នកស្រី រិទ្ធិ សំអុល |
| 15:30 – 15:45 | សំរាកអាហារសំរន់ | |
| 15:45 – 17:30 | យល់ដឹងអំពីអ្នកទេសចរណ៍ និងតំរូវការរបស់ពួកគេ | លោក ម៉ែន ប្រាជ្ញវុទ្ធី |
| **ថ្ងៃទី២ : ថ្ងៃអង្គារ ទី២២ ខែសីហា ឆ្នាំ២០០៦** | | |
| 08.00 – 12:00 | ប្រព័ន្ធទេសចរណ៍ : របៀបដំណើរការវិស័យទេសចរណ៍ | Dr. Trevor Sofield<br>លោក វ៉ាន់ ស៊ី |
| 12.00 – 14.00 | សំរាកបាយថ្ងៃត្រង់ | |
| 14:00 – 15:30 | គោលគំនិតស្តីពីសហគមន៍គ្រប់គ្រងទេសចរណ៍ | លោក ម៉ែន ប្រាជ្ញវុទ្ធី |
| 15:30 – 17:30 | ការជ្រើសរើសទីតាំង បុរេលក្ខខណ្ឌ និងឧបករណ៍សំរាប់សហគមន៍ទេសចរណ៍ | លោក យិន សូរិយា |
| **ថ្ងៃទី៣ : ថ្ងៃពុធ ទី២៣ ខែសីហា ឆ្នាំ២០០៦** | | |
| 07:30 – 10:30 | ធ្វើដំណើរទៅកាន់រមណីដ្ឋានទឹកធ្លាក់ចំបក់ ខេត្តកំពង់ស្ពឺ | លោក ហាក់ សុខលាភ |
| 10:30 – 11:00 | ណែនាំអំពីការចុះសិក្សានៅមូលដ្ឋាន និងទីតាំងភូមិសាស្ត្រភូមិក្នុងឃុំចំបក់ | លោក វ៉ាន់ ស៊ី និងទូច ម៉ន |
| 11:00- 13:30 | ដំណើរកំសាន្តទៅទឹកធ្លាក់ និងពិសារបាយថ្ងៃត្រង់ | លោក ហាក់ សុខលាភ |
| 14:30 – 17:00 | ការចុះអនុវត្តជាក់ស្តែងនៅមូលដ្ឋាន | លោក វ៉ាន់ស៊ី |
| 17:00 – 17:30 | ពិសារបាយល្ងាច និងការណែនាំអំពីការស្នាក់នៅ ផ្ទះសំណាក់សហគមន៍ | លោក ហាក់ សុខលាភ |
| **ថ្ងៃទី៤ : ថ្ងៃព្រហស្បត្តិ ទី២៤ ខែសីហា ឆ្នាំ២០០៦** | | |
| 08:00 – 08:30 | បទបង្ហាញតាមក្រុម ពីលទ្ធផលចុះអនុវត្តជាក់ស្តែងនៅមូលដ្ឋាន | តំណាងក្រុម និងវ៉ាន់ ស៊ី |
| 08:30-08:45 | ការឆ្លុះបញ្ចាំងលទ្ធផលចុះអនុវត្តជាក់ស្តែងនៅមូលដ្ឋាន | លោក ម៉ែន ប្រាជ្ញវុទ្ធី |
| 08:45 – 12:00 | ផែនការរៀបចំសហគមន៍ទេសចរណ៍ (វិធីសាស្ត្រ និងឧបករណ៍) | លោក ម៉ែន ប្រាជ្ញវុទ្ធី |
| 12:00 – 13:30 | ពិសារបាយថ្ងៃត្រង់ | លោក ហាក់ សុខលាភ |
| 13:30 – 16:30 | ផែនការរៀបចំសហគមន៍ទេសចរណ៍ធម្មជាតិ (វិធីសាស្ត្រ និងឧបករណ៍) | លោក ម៉ែន ប្រាជ្ញវុទ្ធី |
| **ថ្ងៃទី៥ : ថ្ងៃសុក្រ ទី២៥ ខែសីហា ឆ្នាំ២០០៦** | | |
| 08:00 – 08:30 | សង្ខេបមេរៀនដែលបានរៀន | អ្នកចូលរួម |
| 08:30 – 10:00 | ការអនុវត្តគំរោងសហគមន៍ទេសចរណ៍ និង អតិបរមាកម្មផលកំរៃ | លោក យិន សូរិយា |
| 08:00 – 12:00 | ការតាមដាន និងការវាយតំលៃសហគមន៍ទេសចរណ៍ (ករណីសិក្សាចំបក់) | លោក ម៉ែន ប្រាជ្ញវុទ្ធី |
| 12.00 –13:00 | ពិសារបាយថ្ងៃត្រង់ | លោក ហាក់ សុខលាភ |
| 13:00 – 13:30 | មើលវីដេអូស្តីពីអេកូទេសចរណ៍ | លោក យិន សូរិយា |
| 13:30 – 15:30 | លំហាត់ការតាមដាន និងការវាយតំលៃសហគមន៍ទេសចរណ៍ | លោក យិន សូរិយា |
| 15:30 – 16:30 | ផែនការសកម្មភាពក្រោយចប់វគ្គ | លោក សួស ពិនរក្ស |
| 16:00 – 17:00 | មតិផ្តាំផ្ញើ និង ចែកវិញ្ញាបនប័ត្របញ្ជាក់ការសិក្សា | អ្នកសំរបសំរួលវគ្គ |

**អ្នកសំរបសំរួល :**

- អ្នកសំរបសំរួលពីសកលវិទ្យាល័យភូមិន្ទភ្នំពេញ ៤ រូប
- អ្នកសំរបសំរួលពីអង្គការ CCBEN ១ រូប
- អ្នកសំរបសំរួលពីភី.អ៊ិល.ជី/សិលា ២ រូប

## ថ្ងៃទី១ : ថ្ងៃច័ន្ទ ទី២១ ខែសីហា ឆ្នាំ២០០៦

- ការណែនាំខ្លួន និងការរំពឹងទុករបស់សិក្ខាកាមបន្ទាប់ពីបញ្ចប់វគ្គបណ្តុះបណ្តាល
  - នឹងបានស្គាល់អ្វីដែលហៅថា អេកូទេសចរណ៍ ?
  - នឹងបានយល់ដឹងពីដំណើរការរៀបចំ សហគមន៍ទេសចរណ៍ធម្មជាតិ
  - នឹងបានដឹងពីយុទ្ធសាស្ត្រក្នុងការបង្កើត សហគមន៍ទេសចរណ៍ធម្មជាតិ
  - នឹងបានចង់ដឹងថា តើធ្វើយ៉ាងម៉េចអោយសហគមន៍ចូលរួមក្នុងសហគមន៍ទេសចរណ៍ធម្មជាតិ ?
  - នឹងអាចយកចំណេះដឹង និងជំនាញពីការរៀនសូត្រទៅអនុវត្តគំរោង
- បទបញ្ជាផ្ទៃក្នុង
  - ម៉ោងសិក្សា : ពេលព្រឹក ៨:០០-១២:០០ និងពេលរសៀល ២:០០-៥:៣០
  - គោរពពេលម៉ោងសិក្សា (ដាក់ពិន័យអ្នកមកយឺត)
  - បិទ ឬបន្ថយសំលេងទូរសព្ទ័ចៀសវាងការរំខាន
  - ហាមនិយាយកាត់ ឬនិយាយរំខាន
  - លើកដៃ មុននឹងមានយោបល់ និងមានសំណួរ
  - សំរាក១៥ នាទី (២ដងក្នុងមួយថ្ងៃ)
- គោលគំនិតជាមូលដ្ឋានស្តីពីទេសចរណ៍ : និយមន័យ ប្រភេទ អ្នកទេសចរណ៍ពិភពលោក និងនៅប្រទេសកម្ពុជា ដោយអ្នកស្រី រិត សំអុល ដេប៉ាតឺម៉ង់ទេសចរណ៍ សាកលវិទ្យាល័យភូមិន្ទភ្នំពេញ ។ ប្រធានបទបង្ហាញរួមមាន :

  ១- និយមន័យនៃទេសចរណ៍/ភ្ញៀវទេសចរ

  ២- សារៈសំខាន់ និងផលប៉ះពាល់

  ៣- ប្រភេទនៃទេសចរណ៍

  ៤- អេកូទេសចរណ៍ : ភាពជោគជ័យ និងបរាជ័យ

## ១_ និយមន័យនៃទេសចរណ៍/ភ្ញៀវទេសចរ

## ផ្នែកតម្រូវការ

ទេសចរណ៍ គឺជាការបម្លាស់ទីបណ្តោះអាសន្ន ឬរយៈពេលខ្លី របស់មនុស្ស ទៅកាន់តំបន់គោលដៅក្រៅពីកន្លែងដែលពួកគេរស់នៅ និងធ្វើការប្រចាំថ្ងៃ ។ ការបម្លាស់ទីភាគច្រើនគឺមានលក្ខណៈជាអន្តរជាតិ និងជាសកម្មភាពកម្សាន្ត។ Burkart and Medlik, 1981:V

ទេសចរណ៍ គឺជាបណ្តុំនៃបាតុភូត និងទំនាក់ទំនងដែលកើតចេញពីអន្តរទំនាក់ទំនងនៃភ្ញៀវទេសចរ អ្នកផ្គត់ផ្គង់ផ្នែកពាណិជ្ជកម្ម រដ្ឋាភិបាលម្ចាស់ផ្ទះ និងសហគមន៍នៅក្នុងដំណើរការនៃការទាក់ទាញ និងទទួលភ្ញៀវទេសចរ ទាំងនេះ និងអ្នកទស្សនាដទៃទៀត ។ Mcintosh & Gorldner, 1990:5

## ផ្នែកផ្គត់ផ្គង់

ឧស្សាហកម្មទេសចររួមមាន សហគ្រាស ស្ថាប័ន និងសម្បទាទេសចរណ៍ដែល មានបំណងបម្រើតម្រូវការជាក់លាក់ និងការចង់បានរបស់ភ្ញៀវទេសចរ ។ Leiper 1979: 400

## ៦. សារៈសំខាន់ និងផលប៉ះពាល់ *( ចែកជាបីក្រុម ដើម្បីពិភាក្សា ហើយបង្ហាញដល់ក្រុមធំ)*

### ក្រុមទី១

* ផលប៉ះពាល់អវិជ្ជមាន :
  - សេដ្ឋកិច្ចមានការកើនឡើងតែសេដ្ឋកិច្ចរបស់ប្រជាពលរដ្ឋមូលដ្ឋានមិនកើនឡើង។
  - ប្រជាពលរដ្ឋបានធ្វើចំណាកស្រុក
  - បានផ្លាស់ប្តូរពីតំបន់ធម្មជាតិ (វាលស្មៅស្រស់បំព្រងក្លាជាសំណង់អាគាធំៗ)
  - ការដកហូតផលប្រយោជន៍ធនធានធម្មជាតិហួសកំរិត

### ក្រុមទី២

* ផលប៉ះពាល់វិជ្ជមាន
  - សេដ្ឋកិច្ចកើនឡើងសំរាប់អ្នកវិនិយោគ សហគមន៍
  - សង្គមវប្បធម៌ : ទទួលចំណេះ វប្បធម៌ជឿនលឿន
  - បរិស្ថាន : សោភណ្ឌភាពកើនឡើងតាមលក្ខណៈកែច្នៃ
* ផលប៉ះពាល់អវិជ្ជមាន
  - ប្រាក់ចំណូលភាគច្រើនបានសហគ្រិន
  - បាត់បង់មុខរបរពីបុរាណ

- បាត់បង់ប្រពៃណី វប្បធម៌
- ចំណាកស្រុក
- គ្មានសមត្ថភាពក្នុងការទទួលចំណេះដឹងថ្មី
- កំណើននៃការបំពុល
- ខូចប្រព័ន្ធអេកូឡូស៊ី



**<u>ក្រុមទី៣</u>**

* ផលវិជ្ជមាន :

˙ សេដ្ឋកិច្ច :

- ទាក់ទាញអ្នកវិនិយោគ
- ប្រជាជនមានមុខរបរ និងការងារ
- មានទីផ្សារកើនឡើង

˙ សង្គម-វប្បធម៌ :

- ការរស់នៅមានលក្ខណៈទំនើប
- មុខរបរផ្លាស់ប្តូរ



ក្រុមពិភាក្សា

˙ បរិស្ថាន :

- បរិស្ថាន ឧស្សាហកម្មជឿនលឿន (កន្លែងលំហែរ)

* ផលអវិជ្ជមាន :

˙ សេដ្ឋកិច្ច :

- បោះបង់ចោលការនេសាទប្រពៃណី
- ចំនូលបានទៅលើអ្នកមាន

˙ សង្គម-វប្បធម៌ :

- ចប្បធម៌បរទេសហូរចូល
- ចំណាកស្រុកច្រើន
- បាត់បង់ទំនៀមទំលាប់ប្រពៃណី



ការបង្ហាញលទ្ធផលក្រុមពិភាក្សា

˙ បរិស្ថាន :

- បរិស្ថានធម្មជាតិត្រូវបានកែច្នៃ
- វិសមភាពនៃការគ្រប់គ្រងកាកសំណល់
- បាត់ភ្ញៀវទេសចរតាមបែបធម្មជាតិ

## ៣. ប្រភេទនៃទេសចរណ៍

-ទេសចរណ៍វប្បធម៌ : វប្បធម៌, ជនជាតិ, ប្រវត្តិសាស្ត្រ និង បុរាណវិទ្យា ។

-ទេសចរណ៍ធម្មជាតិ : ធម្មជាតិ, ការផ្សងព្រេង, សត្វព្រៃ និង អេកូទេសចរណ៍ ។

(សូមមើលរៀនដែលមានជូនភ្ជាប់)



ថ្ងៃទី២ : ថ្ងៃអង្គារ៍ ទី២២ ខែសីហា ឆ្នាំ២០០៦

**ប្រធានបទ :**

១. ប្រព័ន្ធទេសចរណ៍ : របៀបដំណើរការវិស័យទេសចរណ៍ ប្រព័ន្ធមានទំរង់ពីរ គឺ ១).ក្របខ័ណ្ឌការងារ (Framework) និង២).ទំនាក់ទំនងរវាងសកម្មភាពរវាងផ្នែកនីមួយៗរបស់ រចនាសម្ព័ន្ធ (Clockwork) ។ ឧទាហរណ៍អំពីសរីរាង្គមួយនៅក្នុងប្រព័ន្ធជីវសាស្ត្រ រួមមាន ជំរក បរិយាកាស (ឧស្ម័នកាបូនិច) អាកាសធាតុ (ពន្លឺថ្ងៃ) ទឹក (ជីជាតិ) និងដី។

ទេសចរណ៍ជាប្រព័ន្ធ : មនុស្សជាច្រើនគិតថា ទេសចរណ៍ផ្តោតលើវិស័យ៣ (គោលដៅ ដែលមានការទាក់ទាញ និងសកម្មភាពរបស់ពួកគេ, ទីផ្សារ ឬតំបន់បង្កើតអ្នកទេសចរ និងវិស័យដឹកជញ្ជូន...) ។ ទោះជាយ៉ាងណាក៏ដោយទេសចរណ៍នឹងមិនអាចកើតមានទេ ប្រសិនបើរចនាសម្ព័ន្ធ៤យ៉ាង គឺ

- ○ វិស័យគាំទ្រសេវាកម្ម
- ○ វិស័យរដ្ឋាភិបាល
- ○ បរិស្ថានជីវរូប
- ○ សហគមន៍

រចនាសម្ព័ន្ធទាំង៧នេះ បង្កើតបានជាក្របខ័ណ្ឌនៃប្រព័ន្ធទេសចរណ៍ (framework) ហើយទំនាក់ទំនងរាប់រយរបស់វាបង្កើតបាន ជាក្របខ័ណ្ឌ Clockwork) ។



២. គោលគំនិតស្តីពីសហគមន៍ទេសចរណ៍

៣. ការជ្រើសរើសទីតាំង បុរេលក្ខខណ្ឌ

ថ្ងៃទី៣ : ថ្ងៃពុធ ទី២៣ ខែសីហា ឆ្នាំ២០០៦

-ធ្វើដំណើរទៅកាន់រមណីដ្ឋានចំបក់ ខេត្តកំពង់ស្ពឺ



១-ណែនាំអំពីការចុះសិក្សានៅមូលដ្ឋាន




២-ណែនាំពីទីតាំងភូមិសាស្ត្រ



៣-ដំណើរកំសាន្តទៅកាន់ទឹកធ្លាក់



៤-ពិសារបាយថ្ងៃត្រង់ នៅទឹកធ្លាក់



៥- ការចុះអនុវត្តជាក់ស្តែងនៅមូលដ្ឋាន



៦-ណែនាំអំពីការស្នាក់នៅក្នុងឃុំចំបក់

ថ្ងៃទី៤ : ថ្ងៃព្រហស្បតិ៍ ទី២៤ ខែសីហា ឆ្នាំ២០០៦

-បទបង្ហាញតាមក្រុមពីលទ្ធផលចុះអនុវត្តជាក់ស្តែងនៅមូលដ្ឋាន (ឃុំចំបក់) និងការឆ្លុះបញ្ចាំងលទ្ធផលចុះអនុវត្តជាក់ស្តែង ។

**ក្រុមទី១ : ធនធានទេសចរណ៍**

១. ធនធានធម្មជាតិ និងកិរិតពិន្ទុ :

- ទីតាំង (៥) មានទំហំ១៦១ ហ.ត ធម្មជាតិពិត១ មានព្រៃ សត្វព្រៃ ទឹកធ្លាក់
- ទេសចរណ៍ (៤) មានលក្ខណៈធម្មជាតិសុទ្ធសាធ
- កន្លែងទស្សនាទេសភាព (៣) មានកន្លែងទស្សនាតិច
- ទេសភាពជនបទ (៤) មានលក្ខណៈសមស្របតាមប្រពៃណី
- ទឹកធ្លាក់ (៥) មានទេសភាពល្អទឹកធ្លាក់ខ្ពស់ស្អាតត្រជាក់
- រូងភ្នំ (៤) មានសត្វប្រចៀវនៅតែមិនសូវទាក់ទាញភ្ញៀវក្នុងស្រុក
- បឹង (៣) បានរក្សាលក្ខណៈធម្មជាតិ
- ព្រៃ (៤) មិនសូវសំបូរដើមឈើធំៗ តែសំបូររុក្ខជាតិច្រើនប្រភេទ
- រុក្ខជាតិផ្កា (៣) មានតែផ្កាព្រៃធម្មជាតិ
-រដូវផ្ការីក (៤) ពេលនេះមិនសូវមានតែមានច្រើននៅពេលបុណ្យចូលឆ្នាំ (សួរអ្នកស្រុក)
- ផលិតផលកសិកម្ម (២) មានដំណាំស្រូវ
- ប្រភេទសត្វព្រៃ (៣) សំបូរសត្វឈ្លូស ជ្រូកព្រៃ និងស្វា
- ឱកាសមើលសត្វព្រៃ (២) មិនទាន់មានសត្វព្រៃសាំងដែលអាចមើលពេលថ្ងៃបាន
- ប្រពន្ធ័ជីវៈចំរុះ (ជីវៈស្ថានដែលងាយរងគ្រោះ)(៤) មានការគ្រប់គ្រងបានល្អ
- ភាពទាក់ទាញធម្មជាតិដែលលេចធ្លោ (៥) ទឹកធ្លាក់ទេសភាពព្រៃភ្នំ
- ឱកាសកំសាន្ត (៤) មានភ្ញៀវមកជាបន្តបន្ទាប់ភាគច្រើនបុណ្យចូលឆ្នាំ អាចមានដល់១០០០នាក់

× យោបល់: ជាទីតាំងដែលមានសក្តានុពល និងស្ថិតក្រោមការគ្រប់គ្រង ដែនការពារធម្មជាតិ ។ ប៉ុន្តែកន្លែងដែលទេសចរណ៍ទស្សនាកំសាន្តនៅមានតិច ដោយមានតែទឹកធ្លាក់ និងរូងប្រចៀវ ។ គួររៀបចំកន្លែងកំសាន្តអោយបានច្រើនដើម្បីទាក់ទាញភ្ញៀវអោយសាក់នៅយូរ ។

**ក្រុមទី២ : ធនធានវប្បធម៌**

១. ប្រវត្តិ :

ឃុំចំបក់មាន៩ភូមិ មានប្រជាជនប្រមាណ ៧៤២គ្រួសារ ។ កាលពីដើមឡើយឃុំនេះមានឈ្មោះថា ចាំបក់ ។

២. សាសនា :

-ប្រជាជន៩៩% កាន់សាសនាព្រះពុទ្ធ

-មានវត្តចំនួន ១កន្លែង

៣. ទំលៀមទំលាប់ និង ប្រពៃណី

-ជាទូទៅពេលប្រជាជនមានជំងឺ មិនទាន់ទៅពេទ្យទេ

-ប្រជាជននៅទីនោះភាគច្រើនមានតំណមមិនហូបសាច់ទន្សាយ

-រៀងរាល់ឆ្នាំតែងតែមានពិធីសែនព្រេនសុំទឹកភ្លៀង

៤. ប្រវត្តិកន្លែងកំសាន្ត : កាលពីដើមទឹកធ្លាក់បានហូរលាន់លឺខ្លាំង ហើយព័ទ្ធសៀមបានវាយបំបែក ។

៥. ជីវភាពរស់នៅរបស់ប្រជាជនក្នុងឃុំចំបក់

-ពីមុនពួកគាត់ធ្វើស្រែចំការ និងបន្ទាប់បន្សំ កាប់ឈើលក់ និងបង្កើតឡផ្សេង...។

-ក្រោយមក អង្គការម្លប់បៃតងគាំទ្របង្កើតសកម្មភាពគំរោង ប្រជាជននៅទីនោះបានផ្លាស់មុខរបរ ។

យោបល់រួម : គណៈកម្មការសហគមន៍ និង អាជ្ញាដែនដី ស្ថាប័នជំនាញគួរតែរួមសហការស្វែងរកម្ចាស់ជំនួយមកបន្តជួយធ្វើការអភិវឌ្ឍន៍តំបន់នេះតទៅទៀត ។

**<u>ក្រុមទី៣</u> : ចំណេះដឹង និងជំនាញ**

-សាលារៀនមាន ១ខ្នងមាន ៥បន្ទប់ (ថ្នាក់ទី១-៥)

-ចំនួនកំរិតសិស្ស ២៨០ នាក់ (ថ្នាក់ទី១-២-៣ ភាគច្រើន)

-ភាគរយនៃអ្នកចេះអក្សរ ២០% (អាចអាន និងសរសេរបាន)

-ភាពដឹកនាំរបស់គណៈកម្មការទេសចរណ៍ : មានសមត្ថភាពដោះស្រាយបទល្មើស និងបញ្ហាផ្សេងៗ

-ការងារទាក់ទងវិស័យទេសចរណ៍: ដឹកភ្ញៀវ លក់វត្ថុអនុស្សាវរីយ៍ លក់សំបុត្រ ធ្វើម្ហូប...

-ជំនាញប្រពៃណី : ធ្វើកញ្ជើរ ឈើច្រត់ ទ្រូ

-បទពិសោធន៍ការងារដែលទាក់ទងជាមួយNGOs: LWS, ម្លប់បៃតង (MB)

-បទពិសោធន៍ ការងារជាមួយរដ្ឋាភិបាល(RGC) បង្រៀនពីវិស័យកសិកម្ម CPA, CF ។

-បទពិសោធន៍ការងារក្រុមហ៊ុន : ខ្លះបានទៅរៀនពីការដេរស្បែកជើង។

-តួនាទីជាប្រពៃណីរបស់នារី : ធ្វើស្រែចំការ និងថែទាំគ្រួសារ។

-ប្រជាជនរៀនពីជំនាញតាមរយៈ អង្គការមកបណ្តុះបណ្តាលនៅក្នុងភូមិ។

-ជំនាញពាណិជ្ជកម្ម : លក់ដូរតូចតាច លក់នំ...។

-ការគិតពីធនធានមនុស្សផ្សេងៗទៀត: មានក្រុមរាំរបាំគោះត្រឡោក ក្រុមភ្លេងប្រពៃណី

យោបល់រួម : ធនធានមនុស្សមានចំណេះទាបហើយមានចំនួនតិច ប៉ុន្តែពួកគេមានឆន្ទៈចូលរួម ។

## ក្រុមទី៤ : អំពីហេដ្ឋារចនាសម្ព័ន្ធ

-នៅក្នុងសហគមន៍ទេសចរណ៍មានផ្លូវលំក្រាលគ្រួសក្រហម ៤ខ្សែ មានប្រវែង១៥គម ។ មណ្ឌលទេសចរណ៍មួយកន្លែងតាមផ្ទះសំណាក់និមួយៗមានបន្ទប់ទឹក និងបង្គន់អនាម័យ មានភោជនីយដ្ឋាន ប៉ុស្តិ៍រដ្ឋបាលឃុំ១ខ្នង។

-ការប្រើប្រាស់សំភារៈប្រភេទហេដ្ឋារចនាសម្ព័ន្ធនៅក្នុងសហគមន៍ទេសចរណ៍ គឺមិនទាន់មានថ្មីទេ។

-ប្រជាពលរដ្ឋនៅក្នុងតំបន់ទេសចរណ៍ជាម្ចាស់

-មានមណ្ឌលទេសចរណ៍សំរាប់ធ្វើការប្រជុំផ្សព្វផ្សាយដល់សហគមន៍ពីការការពារបរិស្ថាន

-សហគមន៍ជាអ្នករៀបចំដោយមានការគាំទ្រពីអង្គការម្លប់បៃតង

-ភ្ញៀវជាតិ និងអន្តជាតិដែលចូលមកទស្សនា

-ផ្លូវលំទាំង៤ខ្សែក្នុងសហគមន៍ទេសចរណ៍ជួយសំរួលក្នុងការរកប្រាក់ចំនូលតាមរយៈការលក់ កសិផលក្នុងសហគមន៍ទេសចរណ៍

-ចំណែកសេវាទូរសព្ទ័មិនទាន់មានគ្រប់គ្រាន់ មណ្ឌលសុខភាពនៅឆ្ងាយ។

## ក្រុមទី៥ : គុណភាពបរិស្ថាន

-ប្រភពទឹក: មានប្រភពទឹកពីស្ទឹងពាមពូល អូរក្រងៃស្នួល ទំនប់បាក់ ទំនប់បឹងស្នួល អណ្តូងស្នប់។

-ការបញ្ចេញកាកសំនល់របស់មនុស្ស សំនល់រលួយដាក់ក្នុងរណ្តៅជីរ (ជីរកំប៉ុស្ត) សំនល់មិនរលួយប្រមូលដុតចោលតាមផ្ទះ។ តាមសហគមន៍ប្រមូលសំរាមដោយភ្នាក់ងារយកមកដាក់ក្នុងរណ្តៅ មានធុងសំរាមតាមផ្លូវ។

-ការជួសជុសអាគារ(គ្មានអាគារដែលមានលក្ខណៈរឹងមាំ)

-ជំរកសត្វព្រៃ : មានសត្វទន្សោង ជ្រូកព្រៃ ឈ្លូសសំបូរ (មានការរំខានពីអ្នកប្រមាញ់ មួយចំនួន)

-ភាពទាក់ទាញបរិស្ថានទូទៅ : ក្នុងភូមិនៅមានព្រៃឈើ ទឹកធ្លាក់ ចំការដំណាំហូបផ្លែ ប្រព័ន្ធផ្លូវលំ ភូមិដ្ឋានមានសោភ័ណ្ឌភាពល្អ។

-ចំនួនភ្ញៀវទេសចរ : ជាមធ្យមក្នុង១ខែ ៥០០នាក់-១០០០នាក់ (ជាតិ និងអន្តរជាតិ)

-ការគំរាមកំហែងសុខភាព : គ្រុនចាញ់ គ្រុនពោះវៀន ផ្តាស់សាយ (គ្មានមណ្ឌលសុខភាព)

-ការគំរាមកំហែងផ្នែកសន្តិសុខ : មានករណីចោរលួចម្តងម្កាល។

**យោបល់រួម** : គុណភាពបរិស្ថាននៅមានភាពល្អប្រសើរ អាចទាក់ទាញទេសចរមកទស្សនាដូចជា : សត្វព្រៃ, ព្រៃឈើ, ទឹកធាក់ភ្នំខ្នងកែវ និងចំបក់, មានការគ្រប់គ្រងកាកសំណល់របស់សហគមន៍បានល្អ ។

## ក្រុមទី៦ : សំភារៈនិងសេវាកម្មទេសចរណ៍

-ការស្នាក់នៅ : មានប្រមាណ២០ផ្ទះសំណាក់សហគមន៍ ដែលអាចស្នាក់នៅបាន ពី៣-៥នាក់ក្នុងផ្ទះនីមួយៗ ។

- មានគ្រែ មុង ភួយ បន្ទប់ទឹក បង្គន់
- តំលៃ ៣ដុល្លា/នាក់/យប់

-កន្លែងបរិភោគ : មានក្នុងសហគមន៍ និងក្រៅ តែត្រូវផ្តល់ដំណឹងមុន

- តំលៃ២ដុល្លា/នាក់/ពេល ( មានម្ហូប៣មុខ)

-អ្នកដឹកជញ្ជូន : មានរទេះគោ ៥០គ្រឿង និងមានកង់ ២០គ្រឿងសំរាប់ជួល និងដឹកភ្ញៀវ

-សត្វពាហន : មានគោ ក្របី ជ្រូក មាន់ ទា

-អ្នកនាំភ្ញៀវ : ការរៀបចំដំបូងមាន១០០នាក់ បច្ចុប្បន្នមានតែ២០នាក់ ដោយចែកវេនគ្នានាំភ្ញៀវឡើងភ្នំ ហើយម្នាក់ៗ ត្រូវទទួលបានកំរៃ៦០០០រៀល/ថ្ងៃ បើមិនបានជូនភ្ញៀវ ពួកគេនឹងទទួលបាន តែ៤០០០រៀល/នាក់ ។

-ហាងក្នុងភូមិ : មានលក់ចាប់ហួយ និងនំនែកបន្តិចបន្តួច ។ ពុំមានហាងបាយទេ ប៉ុន្តែអាចទាក់ទងមុនដើម្បីរៀបចំ ។

-ហាងលក់វត្ថុសប្បកម្មផ្សេងៗ : នៅមជ្ឈមណ្ឌលមានធ្វើវត្ថុអានុស្សាវរីយ៍ដូចជា បណ្តោងសោរ រូបសត្វស្លាបផ្សេងៗ និងវត្ថុអានុស្សាវរីយ៍ផ្សេងៗទៀតមានលក់ថ្ងៃសៅ ថ្ងៃអាទិត្យ និងថ្ងៃបុណ្យដោយទិញយកមកពីក្រៅ ដើម្បីលក់។

-សេវាកម្ម និងពត៌មាន : អាចសួរពត៌មានពីប្រជាពលរដ្ឋអំពីប្រវត្តិទឹកធ្លាក់ ប្រភពទឹកធ្លាក់ ។ ពុំមានសេវាទូរស័ព្ទសាធារណៈ ប៉ុន្តែភ្ញៀវអាចប្រើទូរស័ព្ទផ្ទាល់ខ្លួននៅកន្លែងមួយចំនួនដែលមានសេវា ០១២ និង០៩២ ។

-សំភារៈនិងសេវាផ្សេងៗ : មានរថយន្តឈ្នួល ម៉ូតូឌុបពីចំបក់ទៅផ្លូវជាតិលេខ៤ ។ តំលៃរថយន្ត ២០០០រៀល/នាក់, រីឯម៉ូតូឌុប ៧០០០រៀល/នាក់ ។ ក្នុងឃុំអ្នកភូមិអាចមើលទូរទស្សន៍ និងស្តាប់វិទ្យុបានគ្រប់ប៉ុស្ត៍ ។

-ប្រើប្រព័ន្ធកុំព្យូទ័រសំរាប់កត់ត្រា និងរាប់ក្បាលសំបុត្រ

-រាយការណ៍តាមរយះសិក្ខាសាលាឃុំ

## ក្រុមទី៧ : រដូវកាលបំរើទេសចរណ៍

-រដូវវស្សាខែ ៨-១១ ភ្លៀងច្រើន

-នៅពេលមានពិធីបុណ្យទាន ដូចជាបុណ្យជាតិ បុណ្យចូលឆ្នាំថ្មី និងបុណ្យសិទ្ធិនារី...

-សកម្មភាពទេសចរណ៍តិចនៅខែ៥ ( មិនចំណេញ)

អ្នកទេសចរមកកំសាន្ត បានសិក្សា និង ជួយអប់រំដល់សហគមន៍ផងដែរ ( ជាពិសេសនិស្សិត)

សកម្មភាពដែលពេញចិត្ត ពិសេសការលេងទឹកធ្លាក់ (អ្នកទេសចរខ្មែរ) និងរីឯបរទេសចាប់អារម្មណ៍លើធម្មជាតិ ល្អាងប្រចៀវ ទឹកធ្លាក់...។

ការចំណាយរបស់អ្នកទេសចរណ៍ : ទិញសំបុត្រ ជូលរទេះគោ ជូលឆ័ត្រ ជូលកង់ ទិញវត្ថុអនុស្សាវរីយ៍ ហូបបាយ

-ជាមធ្យមក្នុង១នាក់ ចំណាយប្រហែល ២០,០០០ រៀល (ខ្មែរ) ហើយភ្ញៀវបរទេសចំណាយប្រហែល ១០ដុល្លា ។

យុទ្ធសាស្ត្រ :

-បង្កើតអោយមានសេវាកម្មផ្សេងៗ ដូចជា : អ្នកនាំភ្ញៀវ ការសិក្សាពីតំលៃ និងការចំណេញរបស់ភ្ញៀវ រទេះគោ មគ្គុទេស៍ ការជូលកង់ គុណភាពម្ហូបអាហារ...។

-លើកទឹកចិត្តដល់អ្នកដែលមកធ្វើការសិក្សា (ចុះតំលៃផ្ទះស្នាក់ អនុញ្ញាតិ...)

-បង្កើតការទំនាក់ទំនងជាមួយអាជ្ញាធរ ស្ថាប័ន អង្គការពាក់ព័ន្ធដើម្បីទទួលបានគាំទ្រ

-ផ្សព្វផ្សាយតាមគ្រប់រូបភាព (តាមផ្ទះសំណាក់ សណ្ឋាគារ អ៊ីនធឺណេត ...)

-ដាក់បញ្ចូលសកម្មភាពអភិរក្ស និង អភិរក្សអោយស្ថិតក្នុងផែនការឃុំ ។

-រៀបចំផ្លាកសញ្ញា អប់រំ និង បង្ហាញផ្លូវ ដល់ភ្ញៀវទេសចរ ។

-ប្រជុំបណ្តុញជាមួយសកលវិទ្យាល័យ និងការចូលរួមការចែករំលែកបទពិសោធន៍ផ្សេងៗ ។

**ក្រុមទី ៧ : ទេសចរ [បរិមាណ និង គុណភាព]**

ឆ្នាំ ២០០៥ : (ការវិភាគលើភ្ញៀវទេសចរណ៍)

-ខ្មែរ ១១.២២៣ នាក់ អាយុ៩-៤០ឆ្នាំ (ភ្ញៀវភាគច្រើនមកពីភ្នំពេញភាគ)

-ភ្ញៀវបរទេស ៥៣៣ នាក់ អាយុ៤០ ឆ្នាំឡើងទៅ

ឆ្នាំ ២០០៦ គិតត្រឹមខែសីហា

-ភ្ញៀវខ្មែរ ៦.០០០នាក់

-ភ្ញៀវបរទេស ៣៤០នាក់

គោលបំណងរបស់អ្នកទេសចរ

-៦០%ដើម្បីកំសាន្ត (ខ្មែរ) ២៥% ផ្តោតលើការសិក្សា (សកលវិទ្យាល័យ)

-១៥% ផ្តោតលើការសិក្សាលើវប្បធម៌ និងការរស់នៅរបស់សហគមន៍

-ពួកគេធ្វើដំណើរមកទស្សនាដោយម៉ូតូ (គូរៗ) ឡានក្រុង និងឡានផ្ទាល់ខ្លួន។

ទីតាំងភូមិសាស្ត្រសំរាប់កំសាន្ត :

- មានទឹកធ្លាក់ ៤កន្លែង : ទឹកធ្លាក់ទី១ មានចំងាយ ១.៨០០ម, ទី២ មានចំងាយ ៣.២០០ម, ទី៣ មានចំងាយ ៣.៨០០ម និងទី៤ កំពុងសិក្សារៀបចំ ។

- មានរូងប្រចៀវ ១ កន្លែង ស្ថិតនៅក្នុងផ្ទាំងសិលាភ្នំ។

- កន្លែងទេសចរណ៍ផ្សងព្រេងបរទេស :  កូរេ និងអ៊ឺរុប ឡើងវល្លិ៍ ចំងាយប្រហែល៣.៩០០ម នៅកន្លែងទឹកធ្លាក់ទី៤។ ការកត់ត្រា វិប្រពន្ធ័កត់ត្រា  ១ឆ្នាំបានចំណូល ៤០០០ដុល្លា  ចំណាយអភិវឌ្ឍន៏ផ្សេងៗ ៣២០០ដុល្លា, ចំណាយរដ្ឋបាល ៣០០ដុល្លា ថវិកានៅសល់ត្រូវរក្សាទុកក្នុងទូដែក ។

**<u>ក្រុមទី៨  :  រចនាសម្ព័ន្ធគណកម្មការទេសចរណ៏</u>**




-ចំនួនបុគ្គលិកសរុប : ១៣នាក់  ស្ត្រី ៦នាក់

-តួនាទី : មើលរចនាសម្ព័ន្ធ

-គោលការណ៍ណែនាំ

-លក្ខន្តិកៈ

-បទបញ្ជាផ្ទៃក្នុង

-អ្នកគាំទ្រពីក្រសួងបរិស្ថាន/ទេសចរណ៍  អជ្ញាធរមូលដ្ឋាន ដល់ថ្នាក់ខេត្ត អង្គការមួប់បៃតង

-ការចូលរួមៈ

- ការផ្សព្វផ្សាយអោយប្រជាពលរដ្ឋយល់ពីតំលៃធម្មជាតិ

- ការពារ ដូចជាការដាំកូនឈើ

- ការផ្សព្វផ្សាយបន្ត

- ចូលរួមប្រចាំខែ

- គណៈកម្មការ

-ការបែងចែកផលប្រយោជន៍ មាន៦ភូមិ

- ផ្តល់កំរៃ ជូនអាស្រយ័លើសេវាកម្មជាក់ស្តែង" ធ្វើការក្នុងថ្ងៃនីមួយៗ"

ឧ. -អ្នកអនាម័យ ៤000-៥000 រៀលក្នុងមួយថ្ងៃ

-ប្រធាននាំភ្ញៀវ ៦0 000 រៀលក្នុងមួយខែ

-អ្នកយាមឡាន ១៥0 000 រៀលក្នុងមួយខែ

- គណនេយ្យ ៦0 000 រៀលក្នុងមួយខែ

- មួយភាគធំដល់សហគមន៍

-ចំពោះការប្រើប្រាស់ធនធានធម្មជាតិក្នុងតំបន់ការពារ

- សមជិកសហគមន៍

- ពិនិត្យលទ្ធភាពស្នើសុំ

- បង់វិភាគទាន ៤0ភាគរយ

- អ្នកមិនមែនសមជិកសហគមន៍

- ស្នើសុំពីគណៈកម្មការ

- បង់វិភាគទាន ៧៥ភាគរយ ធៀបតំលៃទីផ្សារ

<u>**ក្រុមទី៩ : អ្នកគាំទ្រពីខាងក្រៅ**</u>

-ក្រសួងបរិស្ថានផ្តល់សិទ្ធិបង្កើត គ្រប់គ្រងបច្ចេកទេសជីភីអេស ផែនទី កំណត់ព្រំប្រទល់ ព្រាងដំណើរការរៀបចំសហគមន៍ក្នុងតំបន់ការពារ សំរបសំរួលការរៀបចំលក្ខន្តិកៈ ។ល។

- អង្គកាម្ជប់បៃតង" ថវិការ ពតិមាន និងពង្រឹងសម្ថភាព"

- ក្រសួងទេសចរណ៍ : គាំទ្រគំនិតទាក់ទាញ ផ្តួចផ្តើម ស៊ីភីអេ

- មន្ទីរបរិស្ថាន : ចូលរួមប្រជុំផ្សព្វផ្សាយដល់អ្នកភូមិ

- កម្មវិធីសិលា : បោះបង្គោលព្រំប្រទល់សហគមន៍

- មន្ទីទេសចរណ៍ : គាំទ្រដំណើរការរៀបចំសហគមន៍ទេសចរណ៍

- ខេអិនភី គាំទ្រដំណើការ និងសិទ្ធិគ្រប់គ្រង

- អាជ្ញាធរមូលដ្ឋាន និងប្រជាពលរដ្ឋ

សហគមន៍ទេសចរណ៍ចំបក់នេះរៀបចំបង្កើតនៅឆ្នាំ២00២ និងសម្ពោធអោយដំណើរការនៅឆ្នាំ២00៣។

មូលហេតុ:

ពេលមុន :ប្រជាជនកាប់ឈើ ដុតធ្យូង បាញ់សត្វអាណាធិបតេយ្យ ប៉ុន្តែឥឡូវនេះពួកគេបង្វែរមុខរបរជាស៊ីភីអេវិញ ។

ដំណើការ:

-កំណត់តំបន់មានសក្តានុពល

-ជ្រើសរើសគណ:កម្មការ

-រៀបចំលក្ខន្តិក:

-ឆ្លងសេចក្តីព្រាងជាមួក្រសួងពាក់ព័ន្ធ

-ក្រសួងផ្តល់សិទ្ធិគ្រប់គ្រង

គោលបំណង:

-ចូលរួមចំណែកការពារព្រៃឈើ សត្វព្រៃ អនុផលព្រៃឈើ

-អប់រំដល់អ្នកភូមិ និងភ្ញៀវទេសចរពីសារ:សំខាន់នៃធនធានធម្មជាតិ និងនិរន្តរភាពប្រើប្រាស់

-រកប្រាក់ចំណូលសហគមន៍

-ផែនការរៀបចំសហគមន៍ទេសចរណ៍ (វិធីសាស្ត្រ និងឧបករណ៍) -សូមមើលឯកសារដែលមានជូនភ្ជាប់

នៅចំនុចនេះមានទាំងមេរៀនស្តីអំពីការកំណត់ទស្សនៈវិស័យ ដោយមានការលែងល្បែងថាមពលមួយដើម្បីកត់សំគាល់មុនសិក្សាពីមេរៀន។ ល្បែងនោះ តំរូវអោយសិក្ខាមទាំងអស់បិតមុខ ហើយត្រូវដើរទៅកាន់គោលដៅដែលបានកំណត់។



**ល្បែងបិទមុខ** : ឆ្លុះបញ្ចាំងអំពីការរៀបចំ និងដឹកនាំក្រុម ដើម្បីអនុវត្តផែនការអោយសំរេចនូវគោលដៅដែលបានកំណត់ ។

**ក្រុម II**

## រចនាសម្ព័ន្ធ សហគមន៍ទេសចរណ៍






ប្រធាន : គ្រប់គ្រងរួមលើសហគមន៍ទាំងមូល

-អនុប្រធាន : ជាជំនួយការរបស់ប្រធាន និង ជាប្រធានស្ដីទីក្នុងករណីប្រធានអវត្តមាន

-រដ្ឋបាល និង ហិរញ្ញវត្ថុ : ត្រួតពិនិត្យថវិកា ការចំណាយ និង ចំណូលរបស់សហគមន៍ និង ត្រួតពិនិត្យបុគ្គលិករៀបចំទុកដាក់ឯកសារ ។

-ផ្នែកផែនការ និង ស្ថិតិ :ត្រួតពិនិត្យ និងវាយតំលៃ

**-ស្ថាប័នពាក់ព័ន្ធ**

-ក្រសួងបរិស្ថាន :- សំរបសំរួលតាមផ្លូវច្បាប់

-ការកំណត់តំបន់

-សិក្សា EIA (សិក្សាផលប៉ះពាល់បរិស្ថាន)

-ផ្ដល់បច្ចេកទេស ។ល។

-ក្រសួងកសិកម្ម :- សំរបសំរួលតាមផ្លូវច្បាប់

-ការកំណត់តំបន់

-សិក្សា EIA ( សិក្សាផលប៉ះពាល់បរិស្ថាន)

-ផ្តល់បច្ចេកទេស ។ល។

-ក្រសួងកសិកម្ម : ស្រាវជ្រាវធ្វើការសិក្សា និង ធ្វើការផែនការអភិរក្សវប្បធម៌ក្នុងតំបន់សហគមន៍

-ក្រសួងទេសចរណ៍ : - សំរបសំរួលតាមផ្លូវច្បាប់

-បណ្តុះបណ្តាលពីមគ្គុទេស

-បណ្តុះបណ្តាលបច្ចេកទេស

-ក្រសួងមហាផ្ទៃ : -រៀបចំគោលនយោបាយក្នុងការសំរបសំរួលចូលក្នុងCIP

-សំរបសំរួលសន្តិសុខក្នុងសហគមន៍

-ទីផ្សារ និងសេវាកម្មៈ-ផ្សព្វផ្សាយពត៌មានទូទៅពីសហគមន៍

-ស្វែងរកទីផ្សា និង បដិសណ្ឋារកិច្ច

-បណ្តុះបណ្តាល និង ពង្រឹងសមត្ថភាពៈ

-TNA

-ធ្វើផែនការបណ្តុះបណ្តាល

-បណ្តុះបណ្តាល

-ត្រួតពិនិត្យ ( វង្វាយតំលៃ)

-ល្បាត : -រៀបចំផែនការល្បាត

-ដំណើរការល្បាត

-កិច្ចសហការជាមួយស្ថាប័នពាក់ពន្ធ័

**លក្ខន្តិកៈ និង បទបញ្ជាផ្ទៃក្នុង**

-ជំពូកទី១ : បទបញ្ញត្តិទូទៅ

-ជំពូកទី២ : រចនាសម្ពន្ធ័ និង តួនាទីភារៈកិច្ច

-ជំពូកទី៣ : ការគ្រប់គ្រង

-ជំពូកទី៤ : ការបែងចែកផលប្រយោជន៍

-ជំពូកទី៥ : បញ្ញត និង ទោសទណ្ឌ

-ជំពូកទី៦ : អវសាននៃបញ្ញាតិ

# រចនាសម្ព័ន្ធសហគមន៍ទេសចរណ៍




តួនាទីអ្នកពាក់ព័ន្ធ

-ក្រសួងបរិស្ថាន ទេសចរណ៍ រដ្ឋបាលព្រៃឈើ

-មន្ទីរបរិស្ថាន មន្ទីរទេសចរ និងរដ្ឋបាលព្រៃឈើ

អាជ្ញាធរមូលដ្ឋាន, អង្គការមិនមែនរដ្ឋាភិបាល

បទបញ្ជាផ្ទៃក្នុង

១. សមាជិកគណៈកម្មការត្រូវចូលរួមប្រជុំជាទៀងទាត់ប្រចាំខែ

២. ហាមកាប់ឈើ, បរបាញ់ក្នុងតំបន់សហគមន៍ការពារ

៣. ហាមដុតព្រៃ, ឆក់ត្រី

៤. ហាមចោលកាកសំណល់ពាស់វាលពាស់កាល

៥. ហាមលេងល្បែងស៊ីសង

៦. ហាមចោះដើមឈើយកជ័រ



# រចនាសម្ព័ន្ធសហគមន៍ទេសចរណ៍ច្រកល្វៀង




-ប្រធាន ១រូប

-អនុប្រធាន ៣រូប

-សេវាកម្ម ០៣រូប

, សន្តិសុខ ០៥ រូប

, រដ្ឋបាល-បេឡា-គណនេយ្យ ៣រូប

, អនាម័យ-សោភ័ណ្ឌភាព ២រូប

, ផែនការអភិវឌ្ឍន៍ ២ រូប



<u>ស្ថាប័នពាក់ពន្ធ័</u>

-មន្ទីរទេសចរណ៍

-មន្ទីរបរិស្ថាន

-រដ្ឋបាលព្រៃឈើ

-មន្ទីររៀបចំដែនដី

-អាជាធរមូលដ្ឋាន និង ដែនដី



-អង្គការសង្គមស៊ីវិល

-វិស័យឯកជន និង សប្បុរសជន

<u>បទបញ្ជាផ្ទៃក្នុង</u>

-ប្រជុំ ១ ខែម្តង និង វិសាមញ្ញករណីពិសេស

-អណត្តិគណៈកម្មការមានរយៈពេល ៣ឆ្នាំ

-សមាជិក គណៈកម្មការស្ត្រី ៤០%

-ករណីមានបញ្ហាអនុវត្តតាមមតិ ៥០+ ១

-គណៈកម្មការបង្កើតឡើងពីការបោះពីសមាជិកសហគមន៍

-ថវិកា ចំណូល

-៤០ភាគរយ អភិវឌ្ឍន៍សហគមន៍ទេសចរណ៍

-៤០ភាគរយ អភិវឌ្ឍន៍ប្រតិបត្តិការ

-២០ភាគរយ ប្រាក់តំកល់



សំណួរ : តើធនធានធម្មជាតិបានប្រើប្រាស់អស់លទ្ធភាពឬនៅ ? បើនៅមានអ្វីខ្លះ ?

ចំលើយ : ធនធានធម្មជាតិបានប្រើប្រាស់មិនទាន់អស់លទ្ធភាពទេ ដូចជា :

-ហេដ្ឋារចនាសម្ពន្ធ័នៅតំបន់ទឹកធ្លាក់

-អភិវឌ្ឍន៍ព្រៃឬស្សី

-ការផ្សំថ្នាំបុរាណ ពីអនុផលព្រៃឈើ និងការស្រាវជ្រាវ

-ផលិតផលត្នោត

-ខ្ទមសំរាកកាយ ( នៅតំបន់ទឹកធ្លាក់)

-ផ្តល់ព័ត៌មាន ( វប្បធម៌ និងប្រវត្តិសាស្ត្រ) និងផ្លាកសញ្ញា( ធំ)

-ការសង្គ្រោះបន្ទាន់

អនុសាន៍ពីសិក្ខាមចំពោះតំបន់ទឹកធ្លក់ចំបក់

-ឯកសណ្ឋាន ( មានហើយ)

-ដាក់ផ្លាកទិសដៅក្នុងភូមិ

-បណ្តុះបណ្តាលជំនាញផ្សេងៗទៀតសំខាន់សំរាប់ចំណូលប្រចាំគ្រួសារ

-ពង្រឹងផ្លូវចូល ( ផ្លាកសញ្ញា)

-ពង្រីកអោយមានការចូលរួមក្នុងការបំរើសេវាកម្មពីអ្នកក្រៅសហគមន៍

-ការធ្វើផែនការយុទ្ធសាស្ត្រ ការផ្សព្វផ្សាយពីផែនការ និងការចូលរួមធ្វើផែនការ

**ការរៀបចំកម្មវិធីទេសចរណ៍**

**កម្មវិធីទៅទស្សនាអេកូទេសចរណ៍នៅភ្នំប្រាំពាន់ ខេត្តក្រចេះ**

***ថ្ងៃទី១***

ម៉ោង ០៧:៣០ ធ្វើដំណើរពីភ្នំពេញទៅដល់ទីរួមស្រុកស្នួល

ម៉ោង ១២:៣០ អាហារថ្ងៃត្រង់នៅផ្សារស្នួល

ម៉ោង ១៤:៣០ សំណេះសំណាលជាមួយក្រុមប្រឹក្សាឃុំស្វាយជ្រះ និងរៀបចំអ្នកនាំផ្លូវ

ម៉ោង ១៥:៣០ នាំក្រុមទៅទស្សនារុក្ខជាតិព្រៃដែលមានដើមគរ និងដើមទ្រាំង

ម៉ោង ១៦:៣០ នាំក្រុមទៅមើលសិប្បកម្មចេញពីស្លឹកទ្រាំង " ភូមិវត្ត "

ម៉ោង ១៧:៣០ សំរាកនៅសាលាឃុំស្វាយជ្រះ ភូមិវត្ត

***ថ្ងៃទី២***

ម៉ោង ០៧:៣០ ស្រស់ស្រូបអាហារពេលព្រឹក

ម៉ោង ០៨:៣០ ធ្វើដំណើរទៅភូមិរំពក

ម៉ោង ០៩:៣០ ជួបសំភាសន៍ពីប្រវត្តិអង្គរនាងអំ ជាមួយគ្រួសារយាអំ

ម៉ោង ១១:៣០ សំរាកបាយថ្ងៃត្រង់

ម៉ោង ១៤:០០ ទៅទស្សនាភ្នំប្រាំពាន់

-ប្រវត្តិភ្នំប្រាំពាន់

-ទស្សនាទឹកចេញពីភ្នំ និងងូតទឹក

-ធ្វើដំណើរឡើងភ្នំ

-មើលអណ្តូងតាព្រហ្ម " ដោយមានភ្ជាប់ ធូប ទៀន និងផ្លែឈើផង "

-សំភាសន៍ឥសី ( ក្រុមវិបស្សនា)

**កម្មវិធីដំណើរទេសចរណ៍ ខេត្តកំពង់ចាម**

***ថ្ងៃទី១***

ម៉ោង ០៨:០០ ជួបជុំដើម្បីនែណាំភ្ញៀវអំពីកម្មវិធី

ម៉ោង ០៨:៣០ ចេញដំណើរទៅកាន់រមណីយដ្ឋាន វប្បធមិ ភ្នំប្រុស ភ្នំស្រី

ម៉ោង ០៩:០០ ទស្សនាទិដ្ឋភាពលើភ្នំប្រុស

-ទស្សនាសត្វស្វា

-ទស្សនាព្រះវិហារ និងរូបចំលាក់គោ

-រូបព្រះពុទ្ធបដិមា

-បណ្ណាល័យ

-មណ្ឌលប្រល័យពូជសាសន៍

ម៉ោង ១២:០០ សំរាកទទួលទានអាហារថ្ងៃត្រង់នៅរម្យនីដ្ឋានភ្នំប្រុស

ម៉ោង ១៤:០០ ដំណើរកំសាន្តឆ្ពោះទៅភ្នំស្រី ដើម្បីទស្សនា និងពិនិត្យមើលទេសភាពពីលើភ្នំស្រី

ម៉ោង ១៦:០០ ទស្សនាតំបន់ប្រាសាទនគរបាជ័យ

ម៉ោង ១៨:០០ សំរាកនៅសណ្ឋាគារមេគង្គ

ម៉ោង ២០:០០ ទទួលទាអាហារពេលល្ងាចនៅភោជណីដ្ឋានបឹងទន្លេមាស

*ថ្ងៃទី២*

ម៉ោង ០៧:៣០ ជួបជុំភ្ញៀវ

ម៉ោង ០៨:០០ ចេញដំណើទៅកាន់រម្យណីដ្ឋាន ទឹកធ្លាក់ហោង មេមុត

ម៉ោង ១០:០០ ទស្សនាព្រៃឈើធម្មជាតិ ទស្សនាល្អាងថ្ម និង ទស្សនាកន្លែងគោរពសក្ការៈ

ម៉ោង ១២:០០ សំរាកទទួលទានអាហារថ្ងៃត្រង់

ម៉ោង ១៣:០០ ងូតទឹកកំសាន្ត

ម៉ោង ១៤:៣០ ធ្វើដំណើទៅចំការឈើហូបផ្លែ និងចំការកៅស៊ូក្រែក

ម៉ោង ១៥:០០ ទស្សនាចំការឈើហូបផ្លែ និងចំការកៅស៊ូក្រែក

ម៉ោង ១៦:៣០ ធ្វើដំណើទៅខេត្តកំពង់ចាម មើលទិដ្ឋភាពចំការកៅស៊ូ និងវាលស្រែ និងមើលទិដ្ឋភាពស្ពានមាត់ឃ្មុង តំបន់លិចទឹក និងនេសាទ។

ម៉ោង ១៩:០០ ទទួលទានអាហារល្ងាច

## កម្មវិធីដំណើរទេសចរណ៍ ក្រុងកែប

*ថ្ងៃទី១*

ម៉ោង ១៤:០០ នាំភ្ញៀវទៅក្រុងកែប

ម៉ោង ១៤:៣០ ភ្ញៀវកំសាន្តឆ្នេរក្រុងកែប និង ទិញវត្ថុអនុស្សាវរីយ៍

ម៉ោង ១៣:០០ អាហារល្ងាច

***ថ្ងៃទី២***

| | |
|---|---|
| ម៉ោង ០៧:០០ | ជួបជុំភ្ញៀវរៀបចំចេញដំណើរ |
| ម៉ោង ០៧:៣០ | ស្រស់ស្រូបអាហារពេលព្រឹក |
| ម៉ោង ០៨:៣០ | ភ្ញៀវធ្វើដំណើរទៅកំសាន្តវប្បធម៌ភ្នំសរសៀរ |
| ម៉ោង ០៩:៣០ | ណែនាំភ្ញៀវអំពីប្រវត្តិ |
| ម៉ោង ១០:០០ | ដំណើរកំសាន្តព្រះចេតិយ៍ព្រះគោត្តម និងដើរមើលរូងភ្នំជីរស និងរូងស្រែមួយរយ |
| ម៉ោង ១២:០០ | សំរាកអាហារថ្ងៃត្រង់ ( បាយកញ្ចប់) |
| ម៉ោង ១៤:០០ | បន្តដំណើរកំសាន្តទៅមើលទេសចរណ៍ធម្មជាតិចំណោកនេសាទ |
| ម៉ោង ១៥:០០ | ធ្វើដំណើរទៅទស្សនា ព្រៃកោងកាងរបស់បាគមន៍ |
| ម៉ោង ១៥:៣០ | ដំណើរកំសាន្តតាមទូក ពិនិត្យមើលសត្វព្រៃ និងព្រៃកោងកាង |
| ម៉ោង ១៧:០០ | ភ្ញៀវត្រឡប់មកវិញ |

**កម្មវិធីដំណើរកំសាន្ត នៅសហគមន៍ទេសចរណ៍** ( គោកដូង ស្រុកអង្គរជុំ ខេត្តសៀមរាប)

***ថ្ងៃទី១***

| | |
|---|---|
| ម៉ោង ០៧:៣០ | ចេញដំណើរពីសៀមរាបទៅភូមិគោកដូង |
| ម៉ោង ០៩:០០ | ទស្សនាតំបន់អភិរក្សព្រៃទឹកជុស |
| ម៉ោង ១២:០០ | សំរាកអាហារថ្ងៃត្រង់ |
| ម៉ោង ១៣:៣០ | ទស្សនាតំបន់ស្ពា និងការពារព្រៃឈើនៅលើភ្នំគោកដូង |
| ម៉ោង ១៦:០០ | ធ្វើដំណើរស្នាក់នៅ Homestay |

***ថ្ងៃទី២***

| | |
|---|---|
| ម៉ោង ០៧:៣០ | ទស្សនាតំបន់អភិវឌ្ឍន៍កសិកម្មតាមគោលការណ៍ធម្មជាតិ |
| ម៉ោង ១១:០០ | អាហារថ្ងៃត្រង់ |
| ម៉ោង ១៤:០០ | ទស្សនាសិប្បកម្ម ( ត្បាញកន្ទេលរំពាក់ និងកៅអីផ្តៅ) |

***ថ្ងៃទី៣***

| | |
|---|---|
| ម៉ោង ០៧:៣០ | ចេញដំណើរសួរសុខទុក្ខអ្នកភូមិនៅជុំវិញបឹងព្រៃទឹកជុស |
| ម៉ោង ០៩:៣០ | ចេញដំណើរត្រឡប់មកក្រុងសៀមរាបវិញ |

## កម្មវិធីដំណើរកំសាន្ត ខេត្តពោធិសាត់

*ថ្ងៃទី១*

ម៉ោង ០៨:០០ ចេញដំណើរទៅតំបន់ទេសចរណ៍ច្រកល្បៀង ល្បាក់កំរោញ

ម៉ោង ០៩:០០ ទស្សនាទេសភាពទឹកធ្លាក់ច្រកល្បៀង

ម៉ោង ១១:០០ សំរាកអាហារថ្ងៃត្រង់ដោយបាយកញ្ចប់

ម៉ោង ១៦:០០ សំរាកនៅផ្ទះសំណាក់សហគមន៍ និងទស្សនាសិល្បៈសហគមន៍

*ថ្ងៃទី២*

ម៉ោង ០៨:០០ ចេញដំណើរទៅភូមិអណ្តែតទឹកកំពង់លួង

ម៉ោង ០៩:០០ ទស្សនាភូមិអណ្តែតទឹក បែរចិញ្ចឹមក្រពើ បែរចិញ្ចឹមត្រី

ម៉ោង ១១:០០ អាហារថ្ងៃត្រង់ដោយបាយកញ្ចប់នៅលើទូក

ម៉ោង ១៤:០០ ទស្សនាសត្វស្លាបនៅកោះស្តេចក្មេង

ម៉ោង ១៦:០០ ទស្សនាផ្សារផលិតផលនេសាទ

*ថ្ងៃទី៣* ធ្វើដំណើរត្រឡប់មកវិញ

## កម្មវិធីដំណើរកំសាន្ត នៅភូមិកាចូន ខេត្តរតនគិរី (វប្បធម៌ជនជាតិទំពួន)

*ថ្ងៃទី១*

ម៉ោង ០៧:៣០ អាហារពេលព្រឹក

ម៉ោង ០៨:០០ ទៅថ្វាយបង្គំព្រះចូលនិព្វានភ្នំឥសីបតិមៈ

ម៉ោង ០៨:៣០ ទស្សនាវប្បធម៌ជានជាតិគ្រឹង តងណងឡិះ

ម៉ោង ០៩:០០ ធ្វើដំណើរទៅស្រុកវ៉ឺនសៃ

ម៉ោង ១០:៣០ ធ្វើដំណើរតាមកាណូត ដល់ផ្លូវភូមិកាចូន

ម៉ោង ១១:៣០ អាហារថ្ងៃត្រង់ (បាយកញ្ចប់)

ម៉ោង ១២:០០ ការវិលត្រលប់ទស្សនាតាមដងទន្លេសេសាន

ម៉ោង ១៤:៣០ ទស្សនាភូមិជនជាតិឡាវ ភូមិបានប៉ុង ភូមិចិន ភូមិវ៉ឺនសៃ ជនជាតិកាចក់ តាមដងអូឡាឡៃ

ម៉ោង ១៥:០០ សំរាកហូបភេសជ្ជៈមូលដ្ឋាន (ស្រាពាង)

ម៉ោង ១៦:០០ ធ្វើដំណើរត្រឡប់កមខេត្តវិញ

ពេលរាត្រី ទស្សនាសិល្បៈជនជាតិភាគតិច

*ថ្ងៃទី២*

| | |
|---|---|
| ម៉ោង ០៧:៣០ | អាហារពេលព្រឹក |
| ម៉ោង ០៨:០០ | ធ្វើដំណើរទៅដល់រម្យណីយដ្ឋានទឹកធ្លាក់ប្រាំពីរជាន់ អូស៊ិនឡៃ ( ទស្សនាទេសភាពទឹកជ្រោះ ងូតទឹក ថតរូប ស្តាប់សំលេងសត្វស្លាប បន្ទាប់មកអាហារថ្ងៃត្រង់បាយកញ្ចប់) |
| ម៉ោង ១៣:៣០ | ទស្សនារណ្តៅត្បូង នៅតំបន់រ៉ែត្បូង |
| ម៉ោង ១៤:៣០ | ទស្សនាជនជាតិ និងកន្លែងឆ្នៃ និងលក់ត្បូង |
| ម៉ោង ១៥:៣០ | ទស្សនារោងចក្រកៅស៊ូក្រែប |
| ម៉ោង ១៦:៣០ | ទិញវត្ថុអនុស្សាវរីយ៍ផ្សារបានលុង |

*ថ្ងៃទី៣*

| | |
|---|---|
| ម៉ោង ០៧:៣០ | ធ្វើដំណើរត្រឡប់វិលវិញ |

**កម្មវិធីដំណើរកំសាន្ត ខ្សែរទស្សនៈកិច្ចទេសចរដោយជិះកង់**ខេត្តមណ្ឌលគីរី

*ថ្ងៃទី១*

| | |
|---|---|
| ម៉ោង ០៨:០០ | ចេញដំណើរពីសែនមនោរម្យ |
| ម៉ោង ១១:០០ | ទៅភូមិពូទ្រេះ ឃុំដាក់ដាំ |
| ម៉ោង ១១:៣០ | អាហារថ្ងៃត្រង់ |
| ម៉ោង ១៣:០០ | ទស្សនាទឹកធ្លាក់ ស្វែងយល់ពីប្រវត្តិភូមិ និងទឹក |
| ម៉ោង ១៨:០០ | អាហារពេលល្ងាច |

*ថ្ងៃទី២*

| | |
|---|---|
| ម៉ោង ០៨:០០ | ចេញដំណើរទៅភូមិពូទ្រ |
| ម៉ោង ១០:៣០ | ទៅភូមិ ស្វែងយលពីជីវិតរស់នៅ និងមុខរបររបស់ជនជាតិដើមភាគតិចព្នង |
| ម៉ោង ១២:០០ | អាហារថ្ងៃត្រង់ |
| ម៉ោង ១៣:០០ | ជិះដំរីទៅលេងទឹកធ្លាក់រម្យនាទី១ |
| ម៉ោង ១៨:០០ | អាហារពេលល្ងាច |

*ថ្ងៃទី៣*

| | |
|---|---|
| ម៉ោង ០៨:០០ | ចេញដំណើរទៅភូមិពូតាំង |
| ម៉ោង ១០:០០ | ជួបចាស់ទុំភូមិ ទស្សានារបាំជនជាតិដើមភាគតិចព្នង ពីវប្បធមិ និងប្រពៃណី |

ម៉ោង ១១:៣០ ធ្វើដំណើរទៅទស្សនាចំការពនេចរ

ម៉ោង ១២:០០ អាហារថ្ងៃត្រង់

ម៉ោង ១៣:០០ ចូលព្រៃមើលសត្វ និងស្តាប់សំលេងតន្ត្រីធម្មជាតិ

ម៉ោង ១៦:០០ ងូតទឹកកំសាន្ត

ម៉ោង ១៨:០០ ធ្វើដំណើរត្រឡប់មកទីរួមខេត្តវិញ

## កម្មវិធីដំណើរកំសាន្ត ខ្មែរទេសចរណ៍កិច្ច ខេត្តកោះកុង

*ថ្ងៃទី១ - ទស្សនាទីរួមខេត្តកោះកុង*

ម៉ោង ០៨:០០ នាំភ្ញៀវទស្សនាវត្តជោត្តញ្ញាណ អំពីប្រវត្តិកកើត និងអ្នកកសាង

ម៉ោង ០៩:០០ ទស្សនា ស្តូកគោរពវិញ្ញាណខន្ធ

ម៉ោង ១០:០០ ទស្សនាផ្សារដងទង់

ម៉ោង ១១:០០ អាហារថ្ងៃត្រង់ នៅភោជនីយដ្ឋានផ្កាយ

ម៉ោង ១២:០០ ជិះអូប៉ូ ទស្សានាទឹកធ្លាក់កោះប៉ោ អំពីប្រវត្តិថ្មដីរ និងថ្មអណ្តែតទឹក

ម៉ោង ១៦:០០ ដំណើរត្រលប់មកសណ្ឋាគារកោះកុង

ម៉ោង ១៧:៣០ អាហារពេលល្ងាចនៅភោជនីយដ្ឋាន ភូមិន្ទកោះកុង

*ថ្ងៃទី២ — ទស្សនាសហគមន៍ទេសចរណ៍ភូមិប៉ាំងតាយាប នៅពាមក្រសោប*

ម៉ោង ០៨:០០ ទស្សនាព្រៃកោងកាងនៅក្នុងសហគមន៍

ម៉ោង ០៩:០០ ទស្សនា ភូមិនេសាទកោះស្រឡៅ

ម៉ោង ១២:០០ អាហារថ្ងៃត្រង់ នៅភូមិកោះស្រឡៅ

ម៉ោង ១៣:០០ ទស្សនាការកែច្នៃផលិតផលកាពិ នៅភូមិកោះកាពិ

ម៉ោង ១៦:០០ អាហារពេលល្ងាចនៅសហគមន៍កោះកាពិ

ម៉ោង ១៨:០០ ទស្សនាសត្វអំពិលអំពែកក្នុងព្រៃកោងកាង

ម៉ោង ២០:៣០ ស្នាក់នៅក្នុងផ្ទះសំណាក់សហគមន៍ភូមិប៉ាំងតាយ៉ាង

## ផែនការទស្សនាអេកូទេសចរណ៍ភូមិព្រែកត្នោត

*ថ្ងៃទី១*

ម៉ោង ០៨:០០ កំពតទៅព្រែកត្នោត

ម៉ោង ០៩:០០ ទស្សនៈកិច្ចព្រៃកន្លោត

ម៉ោង ១០:០០ មើលផលិតផលនេសាទ

ម៉ោង ១១:០០ បាយថ្ងៃត្រង់

ម៉ោង ១៣:០០ ការមុជទឹកសមុទ្រកំសាន្ត

*ថ្ងៃទី ២*

ម៉ោង ០៨:០០ ការឡើងទស្សនាទេសភាពភ្នំបូកគោ "ពពកវិល"

ម៉ោង ១៣:០០ ការជិះទូកទស្សនៈកិច្ចព្រៃកោងកាងតាមស្ទឹងព្រែកត្នោត

## ដំណើរទស្សនានៅក្រុងព្រះសីហនុ

*ថ្ងៃទី០១*

ម៉ោង ០៨:០០ ចេញដំណើរពីទីក្រុងទៅតំបន់ទេសចរណ៍ ទំនប់រលក

ម៉ោង ០៨:៣០ ទស្សនៈអ្នកសហគមន៍ និង ណែនាំភ្ញៀវទៅតំបន់គោលដៅ

ម៉ោង ០៩:០០ ជិះទូកតាមព្រែកក្នុងតំបន់សហគមន៍ដើម្បីទស្សនាៈ ព្រៃកោងកាង សត្វស្លាប ក្តាម ស្វា និង ទេសភាពឆ្នេរសមុទ្រ។

ម៉ោង ១២:០០ ពិសារអាហារថ្ងៃត្រង់នៅលើកោះ និងស្ទូចត្រី

ម៉ោង ១៤:០០ ដំណើរកំសាន្តតាមទូកបន្ត ព្រមទាំងហែលទឹកមើលផ្កាថ្ម ស្មៅសមុទ្រ ត្រី

ម៉ោង ១៥:០០ ដំណើរជិះទូកមើលផ្សោតសមុទ្រ

ម៉ោង ១៧:០០ ធ្វើដំណើរស្នាក់ការសហគមន៍វិញ

ម៉ោង ២០:០០ សំរាកពិសារអាហារពេលល្ងាច

ម៉ោង ២១:០០ សំរាកកំសាន្តពេលរាត្រី

*ថ្ងៃទី ០២*

ម៉ោង ០៨:០០ ពិសារអាហារពេលព្រឹក

ម៉ោង ០៩:០០ ចេញដំណើរត្រឡប់មកក្រុងវិញ

## កម្មវិធីខ្សែទស្សនៈកិច្ចទេសចររម្មណីដ្ឋានធម្មជាតិប៊ូស្រា (១យប់ ២ ថ្ងៃ)

*ថ្ងៃទី០១*

ម៉ោង ០៧:០០ ស្រស់ស្រូបអាហារពេលព្រឹកនៅសែនមនោរម្យ

| | |
|---|---|
| ម៉ោង ០៨:០០ | ចេញដំណើរពីសែនមនោរម្យទៅទឹកជ្រោះប៊ូស្រា |
| ម៉ោង ០៩:០០ | មើលភូមិជនជាតិ និងមើលទេសភាពព្រៃឈើតាមដងផ្លូវ |
| ម៉ោង ០៩:៣០ | ទស្សនា អូប្លាយ |
| ម៉ោង ១០:៣០ | មើលទឹកជ្រោះប៊ូស្រា ( ដំណាក់ទី១ និង ទី២ ) |
| ម៉ោង ១២:០០ | ទទួលទានអាហារថ្ងៃត្រង់ |
| ម៉ោង ១៣:០០ | ងូតទឹកកំសាន្ត |
| ម៉ោង ១៤:០០ | ចេញដំណើរទៅភូមិប៊ូស្រា |
| ម៉ោង ១៨:០០ | ទទួលទានអាហារពេលល្ងាច |
| ម៉ោង ២០:០០ | ទស្សនារបាំជនជាតិ |
| ម៉ោង ២២:០០ | សំរាកពេលយប់ (Nature Lodge) |

*ថ្ងៃទី០២*

| | |
|---|---|
| ម៉ោង ០៧:០០ | ទទួលទានអាហារពេលព្រឹក |
| ម៉ោង ០៨:០០ | ចេញដំណើរទៅកំសាន្តភ្នំណាមល្យេ(០១ថ្ងៃ) |
| ម៉ោង ១៥:០០ | ចេញដំណើរត្រលប់មកសែនមនោរម្យវិញ |
| ម៉ោង ១៧:០០ | មើលថ្ងៃលិចលើកំពូលភ្នំដោះក្រមុំ |
| ម៉ោង ១៨:០០ | ទទួលទានអាហារពេលល្ងាច (សែនមនោរម្យ) |
| ម៉ោង ២០:០០ | សំរាកពេលយប់ |

**ដំណើរកំសាន្តទស្សនាសត្វស្លាបប្រភេទ ត្រយ៉ង ខេត្តព្រះវិហារ (ភូមិត្បាតប៉ើយ នៅសហគមន៍តំបន់អេកូទេសចរណ៍ ខេត្តព្រះវិហារ)**

*ថ្ងៃទី០១*

| | |
|---|---|
| ម៉ោង ០៨:០០ | ធ្វើដំណើរចេញពីភ្នំពេញ (ឡាន) |
| ម៉ោង ១១:០០ | សំរាកអាហារថ្ងៃត្រង់នៅខេត្តកំពង់ធំ |
| ម៉ោង ១៥:០០ | មកដល់ទីរួមខេត្តព្រះវិហារ |
| ម៉ោង ១៦:៣០ | មកដល់តំបន់អេកូទេសចរណ៍ និង ផ្ទះសំណាក់ភ្ញៀវព្រមទាំងកិច្ចស្វាគមន៍ ពីសហគមន៍ |
| ម៉ោង ១៧:៣០ | ទៅទស្សនាសត្វព្រៃ (សត្វស្លាប ) ប្រភេទផ្សេងៗនៅជុំវិញភូមិ (២ គីឡូម៉ែត្រពីភូមិ) |
| ម៉ោង ១៩:០០ | អាហារពេលល្ងាច |

***ថ្ងៃទី០២***

ម៉ោង ០៤:៣០ អាហារពេលព្រឹក (ខ្ចប់យកទៅជាមួយ)

ម៉ោង ០៥:០០ ទស្សនាសត្វស្លាប ទាំងពីរប្រភេទ និង សត្វព្រៃដទៃ

ម៉ោង ១១:០០ អាហារថ្ងៃត្រង់ និង ដើរផ្សារ

ម៉ោង ១៥:០០ ទស្សនាសត្វព្រៃ ឬ សត្វប្រភេទសំខាន់ (បើមិនទាន់ជួប)

ម៉ោង ១៨:៣០ ត្រលប់មកភូមិ

ម៉ោង ១៩:០០ អាហារពេលល្ងាច

***ថ្ងៃទី០៣ : ខេត្តព្រះវិហារ***

ម៉ោង ០៧:៣០ អាហារពេលព្រឹក

ម៉ោង ០៨:៣០ ការដើរកំសាន្តក្នុងភូមិ និង សួរសុខទុក

ម៉ោង ០៩:៣០ ធ្វើដំណើរចេញពីភូមិ

ម៉ោង ១១:០០ អាហារថ្ងៃត្រង់

ម៉ោង ១២:០០ ធ្វើដំណើរចេញពីខេត្ត

ម៉ោង ១៩:០០ មកដល់ភ្នំពេញ

*<u>កំណត់ចំណាំ</u>*

-តំលៃ១៥០$

-រដូវល្អសំរាប់ការមើលសត្វ ខែ តុលា ដល់ មេសា

-ការបរិច្ចាកថវិការបស់ភ្ញៀវទេសចរណ៍សំរាប់ការអភិវឌ្ឍន៍ (តាមចិត្តសប្បុរសធម៌របស់ភ្ញៀវជាតិ)

-ការស្នាក់នៅ ហូបចុក(ក្នុងតំបន់តាមបែបប្រពៃណីប្រជាពលរដ្ឋក្នុងសហគមន៍)

-សំភារៈសំរាប់មើលសត្វ ដូចជា : សាម៉ែល (សូមភ្ញៀវទាំងអស់ត្រៀមដោយខ្លួនឯង)

## ការចូលរួម

 

នៅក្នុងមេរៀននេះអ្នកសំរសំរួលបានលែងល្បែងថាមពលមួយដែលឆ្លុះបញ្ចាំងពីការចូលរួម ។ ល្បែងនេះដោយតំរូវអោយសិក្ខាមចែកចេញជាពីរក្រុម ហើយក្រុមនិមួយៗមិនដឹងពីគោលបំណងរៀងៗខ្លួន នៅទីបំផុតពួកគេត្រូវ ប្រកួតប្រជែងគ្នាដើម្បីអោយដឹងថាការចូលរួមរបស់ក្រុមមួយណាប្រសើរជាងមួយណា។

**សំណួរពិភាក្សា ៖**

១. អ្វីទៅជាការចូលរួម ?

២. ការចូលរួមមានអ្វីខ្លះ?

៣.ហេតុអ្វីត្រូវមានការចូលរួម?

៤.ធ្វើដូចម្តេចអោយមានការចូលរួមច្រើន?

**លទ្ធផលក្រុមពិភាក្សា ៖**

**ក្រុមទី១ ៖**

១. ការចូលរួមជាដំណើរការក្នុងការផ្តល់មតិ យោបល់ គំនិត ការសំរេចចិត្ត ការទទួលខុសត្រូវ ។

២. ការចូលរួម មានទាំងសំភារៈ ថវិកា ពេលវេលា និង កំលាំងពលកម្ម ។

៣. បានជាមានការចូលរួម ៖

-មានគោលបំណងរួមគ្នា

-សហការអនុវត្តការងាររួមគ្នា

-ទទួលបានផលប្រយោជន៍

-យល់ច្បាស់ពីគោលបំណងរួម និងសារៈប្រយោជន៍របស់គំរោង

-តំរូវការពិតរបស់អ្នកចូលរួម

**ក្រុមទី២ :**

១. ការចូលរួមជាការ :

-ជាការចងក្រងគំនិតជាធ្លុងមួយ

-ជាដំណើរការការងារដែលកិច្ចការទាំងនោះចាប់ផ្តើមពីមនុស្សពីនាក់ឡើងទៅ

-ជាការរួបរួមគ្នាដើម្បីសំរេចគោលបំណងអ្វីមួយ

២. ការចូលរួមមាន :

-ដោយផ្ទាល់ : គំនិត ថវិកា សំភារៈ និងពេលវេលា

-ដោយប្រយោល : ការពេញចិត្ត និងមិនមានថវិការជាក់លាក់

៣. បានជាត្រូវមានការចូលរួម :

-ដើម្បីគោលបំណងមួយមានការឯកភាពជាក់លាក់

-ដើម្បីប្រសិទ្ធភាពការងារ និងការទទួលខុសត្រូវ

-ដើម្បីតំលាភាព សាមគ្គីភាព និងភាពជាម្ចាស់

៤. ដើម្បីអោយមានការចូលរួមច្រើនត្រូវ :

-បង្ហាញគោលដៅច្បាស់លាស់

-មានការលើកទឹកចិត្ត

-ការបែងចែកផលប្រយោជន៍មានតំលាភព

-កសាងសម្ពភាព

-ផ្តល់សិទ្ធិអំណាច និងការសំរេចចិត្ត

-និងផ្តល់លទ្ធភាពទៅតាមជំនាញ

**ក្រុមទី៣ :**

១. ការចូលរួមគឺជាការសំដែងមតិ ទស្សនៈរៀង១ខ្លួន ការទទួលខុសត្រូវ និងការសំរេចចិត្តដើម្បីដោះស្រាយបញ្ហាមួយ។

២. ការចូលរួមមានៈ ការផ្តល់មតិយោបល់ ព័តិមាន រៀបចំធ្វើផែនការ អនុវត្តផែនការ ត្រួតពិនិត្យវាយតំលៃ សំភារៈ ថវិកា និងទទួល ផលមានតំលាភាព។

៣. បានជាមានការចូលរួម :

-បង្ហាញពីគោលបំណងច្បាស់លាស់ និង ជាក់លាក់

-ពីផលប្រយោជន៍នៃការចូលរួម

-កសាងទំនុកចិត្ត គណនេយ្យភាព តំលាភាព សមធមិ និងយែនឌ័រ។



៤. ដើម្បីអោយមានការចូលរួមច្រើន :

-ចង់អោយមានការទទួលខុសត្រូវរួមគ្នា

-ចែករំលែកបទពិសោធន៍

-កែប្រែលក្ខណៈ

-ដើម្បីដោះស្រាយបញ្ហារួម

## ១១ជំហានដើម្បីរៀបចំសហគមន៍ទេសចរណ៍



## List of participants with contact phone numbers and email addresses

| No | Name | Position | Institution | Phone | |
|---|---|---|---|---|---|
| 1 | Mr. Suos Pinreak | NREM Coordinator | PLG/Seila PNP | 012 822 977 | pinreak@seila.gov.kh |
| 2 | Mr. Pin Pong Sa | Finance Assistant | PLG/Seila PNP | 011 577 168 | pps@seila.gov.kh |
| 3 | Mr. Sar Kosal | NREM PTA | PLG Pursat | 012 915 363 | nrem.pur@seila.gov.kh |
| 4 | Mr. Sim Saroeun | NREM PFT | ExCom Pursat | 012 879 891 | |
| 5 | Mr. Nouv Sovinn | Office chief | DoT, Pursat | 011 939 204 | |
| 6 | Mr. Chhneang Kirivuth | NREM PTA | PLG, Kratie | 012 850 729 | nremkrt@camintel.com |
| 7 | Mrs. Nhep Pheary | Officer | DoT, Kratie | 011 628 565 | |
| 8 | Ms. Leng Nary | NREM PFT | ExCom, Kratie | 012 267 937 | |
| 9 | Mr. Kim Yon | NREM PTA | PLG, Siem Reap | 012 994 293 | nrem.srp@seila.gov.kh |
| 10 | Mr. Keo Nara | NREM PFT | ExCom, SRP | 012 670044 | |
| 11 | Mr. Chin Vibol | NREM PTA | PLG, SHV | 016 947 736 | nremshv@seila.gov.kh |
| 12 | Mr. Nguon Naren | NREM PFT | ExCom, SHV | 011 746 835 | |
| 13 | Mr. Khy An | NREM PTA | PLG, Koh Kong | 016 825 644 | an_khy@yahoo.com |
| 14 | Mr. Man Phala | NREm PFT | ExCom, KKG | 016 718 335 | |
| 15 | Mr. Ly Vithavann | Vice chief | DoT, Koh Kong | 011 782 923 | |
| 16 | Mr. Suy Thea | NREM PTA | PLG, Kep | 012 915 090 | suythea@hotmail.com |
| 17 | Mr. Sok Chheav | NREM PFT | ExCom, Kep | 092 809 566 | |
| 18 | Mrs. Kim Srey | NREM PTA | PLG, Ratanakiri | 012 956 762 | nrem-rat@camintel.com |
| 19 | Mr. Yin Say | NREM PFT | ExCom, RAT | 012 1930 978 | |
| 20 | Mr. Tranuth Sean | Director | DoT, Ratanakiri | 012 967 043 | |
| 21 | Mr. Mann Mouy | NREM PTA | PLG, MDK | 012 909 907 | mannmouy@yahoo.com |
| 22 | Mr. Khorn Sophoeun | NREM PFT | ExCom, MDK | 011 232 430 | |
| 23 | Mr. Nhorm Sophal | Deputy director | DoE, Mondulkiri | 012 275 131 | |
| 24 | Mr. Sorn Sarun | Office chief | DoT, Mondulkiri | 012 932 104 | |
| 25 | Mr. Uch Chanthol | NREM PTA | PLG, KPC | 012 929 843 | uchhchanthol@yahoo.com |
| 26 | Mr. Moeun Pha | PFT | ExCom, KPC | 012 919 274 | |
| 27 | Mr. Kong Sronos | NREM PTA | PLG, KSP | 012 423 673 | kongsronos@yahoo.com |
| 28 | Mr. Moeung Sen | NREM PFT | ExCom, KSP | 012 828 034 | |
| 29 | Mr. Hak Sokleap | Coordinator | CCBEN, PNP | 012 831 264 | ccben@online.com.kh |
| 30 | Ms. Chea Vicheka | WCS | Phnom Penh | 012 374 658 | vichekachea@gmail.com |
| 31 | Mr. Seng Sitha | LWF | Oral; KSP | 012 571 362 | sintha@lwfcam.org.kh |
| 32 | Mr. Heng Soeng | SCW | Kompot | 012 973 756 | soeng@cambodiaswildlife.org |
| 33 | Mr. Yem Sotee | Cape Diem Travel | Phnom Penh | 012 957 049 | mail@carpe-diem-travel.com |
| 34 | Mr. Men Prachvuthy | RUPP | Phnom Penh | 012 309 121 | mpvuthy@yahoo.com |
| 35 | Mr. Koun Vannsy | RUPP | Phnom Penh | 012 944 912 | vannsykoun@yahoo.com |
| 36 | Ms. Sok Peary | RUPP | Phnom Penh | 011 628 565 | |
| 37 | Mr. Yin Soriya | Chair | CCBEN, PNP | 012 867 117 | yinsoriya@yahoo.com |
| 38 | Dr. Trevor Sofield | Professor | Australia | 092 996 589 | trevors@grm.com.au |

# មូលដ្ឋានគ្រឹះនៃទេសចរណ៍

រិត សំអុល
ដេប៉ាតឺម៉ង់ទេសចរណ៍
សាកលវិទ្យាល័យភូមិន្ទភ្នំពេញ

## មាតិកា

- និយមន័យនៃទេសចរណ៍/ភ្ញៀវទេសចរ
- សារៈសំខាន់ និងផលប៉ះពាល់
- ប្រភេទនៃទេសចរណ៍
- អេកូទេសចរណ៍៖ ភាពជោគជ័យ និងបរាជ័យ

## និយមន័យ : ផ្នែកតម្រូវការ

- ទេសចរណ៍គឺជាការបម្លាស់ទីបណ្ដោះអាសន្ន ឬរយៈពេលខ្លី របស់មនុស្ស ទៅកាន់តំបន់គោលដៅ ក្រៅពីកន្លែងដែលពួកគេរស់នៅ និងធ្វើការប្រចាំថ្ងៃ ។ ការបម្លាស់ទីភាគច្រើនគឺមានលក្ខណៈជាអន្តរជាតិ និងជាសកម្មភាពកម្សាន្ត ។



Burkart and Medlik, 1981:V

## និយមន័យ: ផ្នែកតម្រូវការ

- ទេសចរណ៍គឺជាបណ្ដុំនៃបាតុភូត និងទំនាក់ទំនងដែលកើតចេញពីអន្តរទំនាក់ទំនងនៃភ្ញៀវទេសចរ អ្នកផ្គត់ផ្គង់ផ្នែកពាណិជ្ជកម្ម រដ្ឋាភិបាលម្ចាស់ផ្ទះ និងសហគមន៍នៅក្នុងដំណើរការនៃការទាក់ទាញ និងទទួលភ្ញៀវទេសចរ ទាំងនេះ និងអ្នកទស្សនាដទៃទៀត ។ Mcintosh & Gorldner, 1990:5

## និយមន័យៈ ផ្នែកតម្រូវការ

- ទេសចរណ៍រួមបញ្ចូលសកម្មភាពមនុស្សដែលធ្វើដំណើរទៅ និងស្នាក់នៅកន្លែងក្រៅពី បរិស្ថានទូទៅរបស់ពួកគេក្នុងគោលបំណងកម្សាន្តសប្បាយ ដោយមិនមានរយៈពេល តជាប់គ្នាលើសពី ១ ឆ្នាំ។

WTO & UNSTAT, 1994

## និយមន័យ ៈ ផ្នែកផ្គត់ផ្គង់

- ឧស្សាហកម្មទេសចររួមមាន សហគ្រាស ស្ថាប័ន និងសម្បទាទេសចរណ៍ដែល មានបំណងបម្រើតម្រូវការជាក់លាក់ និងការចង់បានរបស់ភ្ញៀវទេសចរ។



Leiper 1979: 400

## ហេតុអ្វីក៏ច្រើនម្លេះ?

- ទេសចរណ៍គឺជាប្រព័ន្ធមួយដ៏ស្មុគ្រស្មាញ Leiper 1990




## តើមានអ្វីបង្កប់នៅក្នុងនិយមន័យទាំងនេះ?

- គឺជាសកម្មភាពបណ្តោះអាសន្ន, ការធ្វើដំណើររយៈពេលខ្លីរបស់អ្នកក្រៅស្រុក, តាមបណ្តោយផ្លូវឆ្លងកាត់ទៅកាន់ និងមកពីតំបន់គោលដៅ ។
- ប្រហែលជាអាចមានផលប៉ះពាល់ជាច្រើនទៅលើតំបន់គោលដៅ, តំបន់ឆ្លងកាត់ និងប្រភពរបស់ភ្ញៀវទេសចរ
- ប្រហែលជាអាចមានឥទិពលទៅលើចារិកលក្ខណៈរបស់ភ្ញៀវទេសចរ និង
- គឺមានគោលបំណងលំហែ ឬការកម្សាន្តជាចម្បង ទោះបីផ្នែកអាជីវកម្មក៏មាន សារៈសំខាន់ដែរ ។

## និយមន័យភ្ញៀវទេសចរ?

- អ្នកទស្សនាត្រូវបានកំណត់ក្នុងគោលបំណងស្ថិតិដោយអង្គការទេសចរណ៍ពិភពលោក(WTO) ថាជាអ្នកដែលធ្វើដំណើរចេញក្រៅពីបរិស្ថានទូទៅរបស់ពួកគេ ( កន្លែងធ្វើការ និងរស់នៅ) និងដែលមានគោលបំណងចម្បងជាអ្វី១ដែលក្រៅពីសកម្មភាពការងារ ដែលបម្រើ រឺ ផ្តល់ឱ្យពីក្នុងប្រទេស ឬកន្លែងដែលទៅទស្សនា។

## និយមន័យភ្ញៀវទេសចរ?

- បុគ្គលទាំងឡាយណាដែលរស់នៅក្នុងប្រទេសមួយ ដោយមិនគិតពីសញ្ជាតិធ្វើដំណើរ ទៅកន្លែងណាមួយនៅក្នុងប្រទេសនេះមិនលើសពី ២៤ ម៉ោង ឬ ១យប់ ក្រៅពីកន្លែង ដែលពួកគេរស់នៅ ដោយមានគោលបំណងក្រៅពីសកម្មភាពរកប្រាក់ចំណូលនៅក្នុងកន្លែងដែលគេទៅទស្សនា។

WTO, 1981:89

# នរណាជាភ្ញៀវទេសចរ?

- អ្នកដើរកម្សាន្តវិលល្ងាចៈ អ្នកទាំងឡាយណាដែលធ្វើដំណើរទៅទស្សនាកន្លែងមួយ ឬច្រើនដើម្បីសម្រាកលំហែរក្នុងរយៈពេលមួយតិចជាង ២៤ ម៉ោង ។
- ភ្ញៀវទេសចរៈ អន្តរជាតិ - ក្នុងស្រុក



## ប្រភេទនៃទេសចរណ៍

- ទេសចរណ៍វប្បធម៌: វប្បធម៌, ជនជាតិ, ប្រវត្តិសាស្ត្រ និងបុរាណវិទ្យា

## ប្រភេទនៃទេសចរណ៍

- ទេសចរណ៍ធម្មជាតិ: ធម្មជាតិ, ការផ្សងព្រេង, សត្វព្រៃ និងអេកូទេសចរណ៍





# ទេសចរណ៍វប្បធម៌

ផ្តោតសំខាន់ទៅលើវិធីស្វែងយល់ពីជីវិត និងផ្លាស់ប្តូរចំណេះដឹងនិងគំនិត និងការចង់បានបទពិសោធន៍ក្នុងតំបន់, ពិធីបុណ្យ និងប្រពៃណី។



# ទេសចរណ៍ជនជាតិភាគតិច

- ពាក់ព័ន្ធនឹង ប្រពៃណីបុរាណរបស់ជនជាតិដើមភាគតិចយ៉ាងទាក់ទាញ និងជារឿយៗ ប្រជាជនដែលមានលក្ខណៈខុសប្លែកពីគេ ឬការអនុវត្ត វប្បធម៌ដែលកំណត់ជាតិពន្ធុវិទ្យាដែលមានតែមួយ។
- ពេលខ្លះវាមានលក្ខណៈជាន់នឹងទេសចរណ៍វប្បធម៌



## ទេសចរណ៍បុរាណវិទ្យា និងប្រវត្តិសាស្ត្រ

- ផ្តោតទៅលើការទស្សនាតំបន់ដែលមានសារៈសំខាន់ផ្នែក ប្រវត្តិសាស្ត្រ ឬវត្ថុបុរាណវិទ្យាដែលគួរឱ្យកត់សម្គាល់ ដែលកត់សម្គាល់ព្រឹត្តិការណ៍សំខាន់ៗនៃអារិយធម៌ពីអតីតកាល។

## ទេសចរណ៍ធម្មជាតិ

- ទេសចរណ៍ធម្មជាតិកើតឡើងនៅក្នុងបរិបទធម្មជាតិ ប៉ុន្តែមានការសង្កត់ធ្ងន់បន្ថែមទៅលើការពង្រឹងការយល់ដឹង និងការអភិរក្សបរិស្ថានធម្មជាតិ។ វារួមបញ្ចូលការកម្សាន្ត និងការទស្សនាធម្មជាតិជាគោលដៅចម្បង។

## ទេសចរណ៍ផ្សងព្រេង

- មានលក្ខណៈស្រដៀងទៅនឹងទេសចរណ៍ធម្មជាតិ ប៉ុន្តែមានទិដ្ឋភាពខុសគ្នា។
- ទេសចរណ៍ផ្សងព្រេងគឺជាទេសចរណ៍ដែលផ្តោតការយកចិត្តទុកដាក់ទៅលើសកម្មភាពនៅក្នុងតំបន់ធម្មជាតិដែលពាក់ព័ន្ធនឹងបញ្ហាប្រឈមផ្នែករូបវន្ត. ការអប់រំ និងការទាក់ទងជាមួយធម្មជាតិ។



## ទេសចរណ៍សត្វព្រៃ

- ជារឿយៗគុណភាពការរស់នៅរបស់តំបន់ធម្មជាតិ ឬសមាសធាតុនៃជីវិតដែលជារុក្ខជាតិ និងសត្វ ឬសត្វព្រៃដើរតួយ៉ាងសំខាន់ក្នុងការទាក់ទាញភ្ញៀវទេសចរ ទៅកាន់តំបន់គោលដៅជាក់លាក់។
- ទេសចរណ៍សត្វព្រៃស្វែងរកបទពិសោធន៍ដែលអាចឱ្យពួកគេរុករកប្រព័ន្ធអេកូឡូស៊ី និងសត្វទាំងឡាយដែលរស់ក្នុងតំបន់នោះ។





# អេកូទេសចរណ៍

អេកូទេសចរណ៍គឺការធ្វើដំណើរទៅកាន់តំបន់ធម្មជាតិប្រកបដោយការទទួលខុសត្រូវ ដែលអភិរក្សបរិស្ថាន និងកែលំអសុខុមាលភាពប្រជាជនក្នុងតំបន់។



The International Ecotourism Society

# ផលប៉ះពាល់សេដ្ឋកិច្ច

- ចំពោះកំរិតមីក្រូសេដ្ឋកិច្ច
- ចំពោះកំរិតម៉ាក្រូសេដ្ឋកិច្ច



## ផលប៉ះពាល់សង្គម

- សាមគ្គីភាព
- ជម្លោះ និងភាពគ្មានសណ្តាប់ធ្នាប់

ប្រភេទជម្លោះ

- ការកម្សាន្តខាងក្រៅ ទល់នឹង ការប្រើប្រាស់ធនធានដទៃទៀត
- អ្នកកម្សាន្តខាងក្រៅ ទល់នឹង អ្នកគ្រប់គ្រងធនធាន
- ជម្លោះអន្តរកម្ម
- ជម្លោះផ្ទៃក្នុងសហគមន៍



## ផលប៉ះពាល់បរិស្ថាន



# អេកូទេសចរណ៍

អេកូទេសចរណ៍គឺការធ្វើដំណើរទៅកាន់តំបន់ធម្មជាតិប្រកបដោយការទទួលខុសត្រូវ ដែលអភិរក្សបរិស្ថាន និងកែលំអសុខុមាលភាពប្រជាជនក្នុងតំបន់។



The International Ecotourism Society

១៩៩៣

# តើអេកូទេសចរណ៍កើតឡើងនៅពេលណា ដោយមូលហេតុអ្វី?

អេកូទេសចរណ៍កើតនៅទសវត្សរ៍១៩៨០ ដោយមូលហេតុធំៗពីរគឺ

- ការរិចរិលនៃបរិស្ថានធម្មជាតិ
- មនុស្សព្រួយបារម្ភនឹងការបាត់បង់ធនធានធម្មជាតិ និងចង់អភិរក្សធនធានទាំងនេះ



## គោលដៅអេកូទេសចរណ៍

**គោលដៅចម្បងនៃអេកូទេសចរណ៍គឺពង្រឹងការប្រើប្រាស់ប្រកបដោយនិរន្ត
ភាពតាមរយៈ:**

— ការអភិរក្សធនធាន

— ធ្វើឱ្យវប្បធមិរស់ឡើងវិញ

— ភាពសំបូរបែប និងការអភិវឌ្ឍសេដ្ឋកិច្ច

## លក្ខណៈសំខាន់

**លក្ខណៈសំខាន់នៃអេកូទេសចរណ៍រួម
មាន:**

— ផ្អែកទៅលើធម្មជាតិ

— និរន្តភាពនៃអេកូឡូស៊ី

— ការអប់រំផ្អែកបរិស្ថាន

— អត្ថប្រយោជន៍ក្នុងតំបន់ និង

— ការពេញចិត្តរបស់ភ្ញៀវទេសចរ

## យោងទៅតាមទស្សនៈបែបមុខងារ អេកូទេសចរណ៍:

- ភាគច្រើនគឺជា បុគ្គល ឬទេសចរណ៍ក្រុមតូច ( ក្រុមភ្ញៀវទេសចរតិចជាង២៥នាក់ និងសណ្ឋាគារដែលមានគ្រែតិចជាង ១០០គ្រែ)
- ប្រតិបត្តិដោយក្រុមហ៊ុនខ្នាតតូច និងមធ្យមនៅក្នុងតំបន់ធម្មជាតិ
- ផ្តោតសំខាន់ទៅលើការដឹកនាំ និងបំពេញចិត្តក្រុមតូចៗនៅក្នុងតំបន់ធម្មជាតិ ក្នុងលក្ខណៈអប់រំ។

Source: United Nation Environment Program 2001

## តើប្រភេទអាជីវកម្មបែបណាដែលស្ថិតនៅក្នុងក្រុមអេកូទេសចរណ៍?

- ដំណើរទេសចរណ៍ធម្មជាតិដែលមានការណែនាំ ឧ. ការធ្វើដំណើរតាមទូក, ការដើរកម្សាន្តតាមព្រៃ និងទស្សនាសត្វស្លាប
- ដំណើរទេសចរណ៍វប្បធម៌-ប្រវត្តិសាស្ត្រ និងបុរាណវិទ្យា
- កសិទេសរចណ៍



# អ្វីមិនមែនជាអេកូទេសចរណ៍?

- ទេសចរណ៍ខ្នាតធំ
- សកម្មភាព និងការអភិវឌ្ឍមិនសមស្រប

ឧ កាស៊ីណូ បារ ខារ៉ាអូខេ

- នៅពេលដែលភ្ញៀវទេសចរមិនបាន

ទទួលចំនេះដឹងពីដំណើរកំសាន្ត

- នៅពេលដែលគ្មានការគិតគូរអំពី

បរិស្ថាន សង្គម-វប្បធម៌ និង សេដ្ឋកិច្ចមូលដ្ឋាន



# តើនរណាខ្លះជាអេកូទេសចរ?

- អាយុ: ៣៥-៥៤ ឆ្នាំ
- ភេទ: នារី ៥0% និង បុរស ៥0 %
- កម្រិតអប់រំ: ថ្នាក់ឧត្តមសិក្សា ៨២ %
- សមាសភាពក្រុមទេសចរ: ធ្វើដំណើរជាក្រុម ៦0 %
  ,ធ្វើដំណើរជាមួយគ្រួសារ ១៥ % , និងធ្វើដំណើរតែម្នាក់ឯង ១៣ %

Source: Wight 1996 and TIES 2000

# តើពួកគេស្នាក់នៅទីណា?

អេកូទេសចរភាគច្រើនជ្រើសរើសកន្លែងស្នាក់នៅបែបប្រភេទផ្សេងៗ និងមានលក្ខណៈជិតស្និទដូចជា កាប៊ីន ផ្ទះសំណាក់គ្រួសារ ការបោះជំរុំ ឬតំបន់រហោស្ថាន។

Source: Wight 1996 and TIES 2000



# ការគាំទ្របរិស្ថានពណ៌បៃតង

- ៨៣ % នៃអ្នកធ្វើដំណើរជនជាតិអាមេរិកទេរទៅរកការគាំទ្រ ក្រុមហ៊ុនធ្វើដំណើរ "បរិស្ថានពណ៌បៃតង" និងមានបំណងចំណាយជាមធ្យម៦.២ % បន្ថែមសេវាកម្មធ្វើដំណើរ និងផលិតផលដែលផ្តល់ដោយអ្នកផ្គត់ផ្គង់ការធ្វើដំណើរដែលមានការទទួលខុសត្រូវផ្នែកបរិស្ថាន។

Source: The Travel Industry Association of America (1997)

## អត្ថប្រយោជន៍នៃអេកូទេសចរណ៍

- ធ្វើអោយមានលក្ខខណ្ឌដែលមានការកែលំអមួយ(ឧ ការចំណេញ) របស់បុគ្គល ឬក្រុមរបស់បុគ្គល ឬស្ថាប័នមួយផ្សេងទៀត(ឧ. បរិស្ថាន) ។
- ជួយទប់ស្កាត់នូវលក្ខខណ្ឌដែលពុំចង់បាន
- ជួយជំរុញលក្ខខ័ណ្ឌដែលគួរឱ្យចង់បាន

Diver, 1994



## ប្រភេទអត្ថប្រយោជន៍

- ផ្ទាល់ខ្លួន : ផ្នែកចិត្តសាស្រ្ត ផ្នែកសរីរៈសាស្រ្ត
- សង្គម
- សេដ្ឋកិច្ច
- បរិស្ថាន

## តើនរណាខ្លះទទួលអត្ថប្រយោជន៍ពីអេកូទេសចរ?

- អ្នកផ្គត់ផ្គង់ សម្ភារៈ- អ្នកជួលសម្ភារៈ មើលសត្វ. ឡើងភ្នំ និងបោះជំរុំ
- ភោជនីយដ្ឋាន-ការធ្វើអាហារក្នុងតំបន់
- ការលក់វត្ថុសិប្បកម្ម-ក្អមឆ្នាំង. សម្លៀកបំពាក់ ការងារសិល្បៈក្នុងតំបន់
- កន្លែងស្នាក់នៅ : ផ្ទះសំណាក់គ្រួសារ
- ផ្សេងៗទៀត?



## តើអ្នកធ្វើយ៉ាងណាទើបបានទទួលទេសចរ?

ធ្វើការផ្សព្វផ្សាយរចំពោះអេកូទេសចរ

- ចូរចងចាំថាពួកគេខុសប្លែកពីទេសចរដទៃទៀត
- ពួកគេចង់បានលក្ខណៈធម្មជាតិ និង មានទ្រង់ទ្រាយតូច ហើយពួកគេមានបំណងចំណាយ ទៅលើលក្ខខណ្ឌនេះ

## តើអ្នកអាចរក្សាទេសចរណ៍ដោយរបៀបណា?

- "បញ្ជាប់" អាជីវកម្មអេកូទេសចរណ៍ទៅនឹងការផ្តល់បទពិសោធន៍បែបចំរុះនៅក្នុងលក្ខណៈមួយដែលងាយស្រួលទទួលយក។
- បណ្តុះបណ្តាល និងអប់រំអ្នកផ្តល់សេវាកម្មអេកូទេសចរណ៍, អ្នកគ្រប់គ្រង និងសមាជិកសហគមន៍ដើម្បីឱ្យអ្នកទស្សនាអាចទទួលបានបទពិសោធន៍ដែលពេញលេញ។

## តើអេកូទេសចរណ៍មានផលប៉ះពាល់អ្វីខ្លះ?

- ចំពោះធនធាន?
- ចំពោះសហគមន៍?
- ចំពោះអ្នកទស្សនា?



## តើអ្នកគ្រប់គ្រងដោយរបៀបណា?



## ការធ្វើផែនការកម្ម

គិតអំពីវិធីសាស្ត្រ និងលទផលមុនពេលអ្នកនាំយកទៅកាន់អ្នកទស្សនា-អេកូ ទេសចរណ៍គឺច្រើនជាងការទទួលភ្ញៀវទេសចរ និងការទទួលផលប្រយោជន៏

# ការត្រួតពិនិត្យ

- ការធ្វើសំណាកផ្ទួនៗនៃវត្ថុដូចគ្នាកន្លងមកដើម្បីរៀបចំឯកសារការផ្លាស់ប្តូរ។

**ហេតុអ្វីត្រូវត្រួតពិនិត្យ?**

- ព្យាករណ៍អនាគត( កំណត់គំរូ)
- កំណត់បញ្ហាសក្តានុពល
- បង្ហាញការផ្លាសប្តូរដែលកំពុងកើតឡើង និង
- រៀបចំដំណើរកម្សាន្តដែលមានគុណភាពខ្ពស់។

# ការអប់រំ

- បង្រៀនអ្នកធ្វើសេចក្តីសម្រេចចិត្តអំពីអត្ថប្រយោជន៍សក្តានុពល និងផលប៉ះ ពាល់ពីអេកូទេសចរណ៍
- បង្រៀនអ្នកប្រតិបត្តិពិធីក្នុងដំណើរការអាជីវកម្មប្រកបដោយនិរន្តភាព នៅពេល ដែលកំពុងការពារធនធាននោះ
- បង្រៀនសមាជិកសហគមន៍ពីរបៀបស្វាគមន៍អ្នកទស្សនា និងផ្តល់បទពិសោធន៍វិជ្ជមាន

## ករណីសិក្សា

## Oceanville សហរដ្ឋអាមេរិក

- Oceanville នៅសហរដ្ឋអាមេរិក គឺជាទីក្រុងតូចមួយដែលមានប្រជាជន ប្រមាណ ៩,០០០នាក់
- វាគឺជាទីក្រុងតូចមួយក្នុងចំណោមទីក្រុងតូចៗមួយចំនួនដែលមាននៅក្នុងតំបន់ ឆ្នេរនៃរដ្ឋនោះ ។
- វិស័យទេសចរណ៍នៅតំបន់នោះបានកើនឡើង៣០០ %នៅ៧ឆ្នាំចុងក្រោយនេះ

## ករណីសិក្សា

## Oceanville សហរដ្ឋអាមេរិក

- អ្នកទស្សនាជាច្រើនចាប់ផ្ដើមធ្វើដំណើរមក Oceanville បន្ទាប់ពីអត្ថបទជាច្រើនត្រូវបានបោះផ្សាយនៅលើទស្សនាវដ្ដីជាតិដែលព្យាយាមធ្វើឱ្យវាក្លាយជាតំបន់គោលដៅដ៏ល្អជាងគេចុងក្រោយមួយ ។
- អ្នកគ្រប់គ្រងក្នុងតំបន់មើលឃើញករណីនេះជាផលប្រយោជន៍សក្ដានុពលសម្រាប់សេដ្ឋកិច្ចក្នុងតំបន់- ការនេសាទបែបពាណិជ្ជកម្មលែងជាសហគ្រាសដែលមានផលប្រយោជន៍ ហើយអ្នកស្រុកត្រូវការប្រភពចំណូលផ្សេងទៀតជាចាំបាច់ ។

## ករណីសិក្សា:

## Oceanville សហរដ្ឋអាមេរិក

- អ្នកគ្រប់គ្រងក្នុងតំបន់ចាប់ផ្ដើមធ្វើការសិក្សាទីផ្សារ តំបន់ធម្មជាតិ និងវប្បធម៌ នៅ Oceanville ត្រូវបានគេស្គាល់យ៉ាងលឿនថាជាទីក្រុងតូចមួយដែលជាកន្លែងសំរាប់ទស្សនាមើល "ថាតើជីវិតធ្លាប់មានលក្ខណៈបែបណា"។
- អេកូទេសចរណ៍បានក្លាយជាឃ្លាំងទាក់ទាញមួយសម្រាប់គ្រប់អាជីវកម្មទាំងអស់ដែលធ្វើជំនួញទៅលើធម្មជាតិ និងវប្បធម៌ទៅតាមវិធីផ្សេងៗ។
- អ្នកស្រុកដែលរស់នៅយូរចាប់ផ្ដើមលក់វត្ថុសិប្បកម្ម, ផ្ដល់ដំណើរកម្សាន្តមើលទេសភាព និងបើកហាងលក់វត្ថុអនុស្សាវរីយ៍ជាច្រើន។

## ករណីសិក្សាទី១:

## Oceanville សហរដ្ឋអាមេរិក

- អ្នកទស្សនាបានដើរជាក្រុមទៅកាន់ទីក្រុងតូចនោះដើម្បីទទួលបទពិសោធន៍នៃ រសនិយមនៅទីកន្លែងនោះ
- ពួកគេក៏បានទៅទស្សនាតំបន់ឆ្នេរ ហើយក៏បានរំភើបចិត្តដែលពួកគេអាចចំណាយពេលជាច្រើនថ្ងៃយ៉ាងសុខសាន្តជាមួយសម្រស់ធម្មជាតិបែបនោះ (សម្រាប់តម្លៃថោក)
- Oceanville ត្រូវបានគេស្គាល់យ៉ាងទូលំទូលាយថាជាតំបន់គោលដៅ ទេសចរណ៍។



## ករណីសិក្សាទី១:

## Oceanville សហរដ្ឋអាមេរិក

- ភាពជោគជ័យរបស់ Oceanville បានទាក់ទាញអ្នកអភិវឌ្ឍ និងអ្នកវិនិយោគ ជាច្រើនទៅកាន់តំបន់នោះ។
- រដ្ឋាភិបាលក្នុងតំបន់បានមើលឃើញថានេះជាប្រយោជន៍មួយផ្សេងទៀតចំពោះសេដ្ឋកិច្ច ហើយស្វាគមន៍ការហូរចូលនៃសាច់ប្រាក់ដែលបានមកពីការសាងសង់សណ្ឋាគារ ខុនដូរ និងផ្ទះវិស្សមកាល។

## ករណីសិក្សាទី១:

## Oceanville សហរដ្ឋអាមេរិក

- នៅក្នុងរយៈពេល ១០ឆ្នាំនៃរុកការនេះ Oceanville បានប្រែប្រួលខុសពី អ្វីជារបស់ខ្លួនពីដើម។
- អ្នកស្រុកភាគច្រើនបានបម្លាស់ទីទៅឆ្ងាយដោយសារតែខ្វះការងារដែលមាន ប្រាក់ខែច្រើន។
- តំបន់ឆ្នេរ និងទីវាលពណ៌បៃតងដែលធ្លាប់បានទាក់ទាញភ្ញៀវអេកូទេសចរ ជាច្រើន ពេលនេះត្រូវបានសាងសង់ជាអគារខ្ពស់ៗដូចជា ខុនដូរ និងផ្ទះឆ្នេរ សមុទ្រដ៏ប្រណីតៗ។



## ករណីសិក្សាទី១:

## Oceanville សហរដ្ឋអាមេរិក

- ទោះបីជាសេដ្ឋកិច្ចនៅក្នុងតំបន់នោះខ្ពស់ សាច់ប្រាក់ភាគច្រើនត្រូវបានគ្រប់គ្រងដោយអ្នកអភិវឌ្ឍធំៗ និងម្ចាស់អាជីវកម្មមួយចំនួន ។
- ប្រជាសាស្ត្រអ្នកទស្សនាទៅកាន់ Oceanville បានផ្លាស់ប្តូរ ហើយអ្នកទស្សនា ទៅកាន់តំបន់ធម្មជាតិ និងវប្បធម៌លែងមកទៀតហើយ ។

## ករណីសិក្សាទី១:

## Oceanville សហរដ្ឋអាមេរិក

លំហាត់ទី១

សូមវិភាគរកផលប៉ះពាល់ដូចខាងក្រោម

- សេដ្ឋកិច្ច?
- សង្គម-វប្បធម៌?
- បរិស្ថាន?

លំហាត់ទី២

- តើមានអ្វីខ្លះខុស?
- តើបំរែបំរួលនេះកើតឡើងដោយរបៀបណា?
- តើអេកូទេសចរណ៍អាចជួយរក្សាសហគមន៍នេះឱ្យនៅក្នុងដៃអ្នកស្រុក នៅខណៈពេលដែលនៅតែផ្តល់ឱកាសសេដ្ឋកិច្ចដោយរបៀបណា?

# Tourism as a System

Professor Trevor Sofield
Team Leader
Mekong Tourism Development Project
CAMBODIA

Team Leader
International Research Group on ST-EP
World Tourism Organization, Madrid

Research Professor, International Centre of Excellence for Sustainable Tourism, STCRC, Australia.

# TOURISM AS A SYSTEM

## A SYSTEM CONSISTS OF:-



**THE FRAMEWORK**
(Structures)

**CLOCKWORK**
(Inter-action/ inter-relationships between various individual components of the structures)



# Analogy with an organism in the biological system




If you remove any structure from the system,

the plant dies.

## TOURISM AS A SYSTEM

Most people think of tourism in terms of three main sectors:

1. The DESTINATION, where attractions and activities are located (the supply side);
2. The MARKET or VISITOR GENERATING REGION, where the potential tourists live (the demand side); and
3. The TRANSPORT SECTOR and the TRANSIT REGION, the zones through which tourists travel by the four different modes of transport (air, road, rail or sea) to get to the destination.





## TOURISM AS A SYSTEM

**VISITOR GENERATING REGIONS** (Demand side)

- **Visitors**
- **Market segmentation**
- Domestic visitors, Regional visitors, International visitors
- *Holiday*
- *Business*
- *Education*
- *Religion (pilgrimage)*

*Sport*
*Conferences, exhibitions, meetings*
*Visiting Friends & Relatives*



*Front line sector agencies/businesses and support services sector deal with Visitors prior to their departure*

## TOURISM AS A SYSTEM

**TRANSIT REGION (Supply side)**




**Major modes of transport take visitors through the transit region to their destination**

*Air*
*Road*
*Rail*
*Sea*

Supported by a host of transport-specific facilities – airports, railway stations, road networks, ports, Fuel depots, engineering and repair facilities, etc.

With a range of ancillary services and facilities:- restaurants, banks, accommodation, communications, retail shops, bookshops, bars, etc.

*Front line sector agencies/businesses and support services sector deal with Visitors in the transit regions. The Government sector also operates here (eg ATCs, Customs)*




TOURISM AS A SYSTEM

◆ **THE DESTINATION (Supply side)**

**The "Frontline Industries Sector"**

Businesses operating directly with visitors **(The Five 'A's)**

- **Accommodation** - hotels, motels, resorts,backpacker hostels, B&B, caravan parks. etc
- **Amenities** - restaurants, sports facilities, theatres, casinos, etc
- **Attractions** (natural and cultural, cities, landscapes, theme parks, museums, events and festivals, etc)
- **Activities** - tour operators, ski fields business companies, yacht charters, bicycle hire, kayaking adventure companies, abseiling, Himalayan trekking companies, etc. etc.
- **Access:** -Travel agencies, transport needs at the destination - Airlines, coaches, trains, cruise ships, taxis, hire cars, bicycles, canoes, horses, etc.

**Note that some of these businesses may also interact with the visitors in the Visitor Generating Region as part of their preparations BEFORE they depart for their destination and also assist them through the Transit Region.**

## Tourism as a system

However, tourism cannot exist without four other supporting structures, each of which contributes to the three structures defined above. These other four structures are:

1. the SUPPORT SERVICES SECTOR;
2. the GOVERNMENT SECTOR;
3. the BIO-PHYSICAL ENVIRONMENT; and
4. COMMUNITY.

Altogether these seven structures make up the framework of the tourism system, and the interaction of their many hundreds of component parts constitute the clockwork.

## Support Industries and Services Sector {invisible}

Backward and forward linkages from Businesses providing goods and services to the frontline operators in both the Visitor Generating Regions and the Destinations

- *A: Architects, Accountants, Advertising Agencies*
- *B: Beverages, Breweries, Banks*
- *C: Credit card agencies, Carriers, Cleani*
- *D: Drainage systems, Decorators*
- *E: Engineers, Electricians, Environmenta consultants, E-mail & Internet*

. . . . . . . . . . . . . .

- *U Uniform manufacturers, Universities*
- *V: Veterinarians, Valuers, Videos*
- *W: Wineries, Welders, Wool products*
- *X: Xray security equipment*
- *Y: Yacht builders, Yarns, "Yellow Pages"*
- *Z: Zinc products, Zinc*






## Government (The Coordination Sector)

Regulatory Controls, Policy Formulation, National Issues and Interests, Planning, Infrastructure, Public ownership

- Regulatory - licensing laws, business registration, taxation, building codes, safety regulations, land title registration, etc.
- Policy - Economic, Tourism, Transport, Foreign Affairs, Sport & Recreation, Education and Training, Regional Development & Decentralisation, Land, Telecommunications
- The Environment - legislation, national parks, biosphere reserves, world heritage sites, etc.
- International Treaties - visas, trade, bilateral air services, anti-terrorist treaties, WHS, etc
- Law & Order - security of visitors, Police, Customs, Immigration, anti-terrorist strategy, etc.
- Infrastructure – roads, railways, airports, water, power, ports, communications systems, etc. (but note increasing role of public sector/private sector partnerships in the provision of infrastructure)
- Public ownership of resources utilised by tourism/tourists: - national museums & art galleries, other public buildings & monuments, squares and other public spaces, sponsorship of major events (Olympic Games, National Days, New Year's Eve, fireworks, cultural festivals, etc).



# TOURISM AS A SYSTEM




If you remove Any one structure from the system then tourism cannot occur.

# TOURISM AS A SYSTEM

- When we begin to understand tourism as a system, we can also challenge the widely held criticism of tourism as a service sector which 'does not produce anything'.

- Just a quick glance at the multiplicity of forward and backward linkages is enough to demonstrate otherwise.

# TOURISM AS A SYSTEM

They will eat:-

- 2.25 million kgs of rice (@ 250gms each per day)
- 2,250,000 kgs of potatoes for french fries (@ a quarter of a kilo each per person per day)





# TOURISM AS A SYSTEM

- They will drink 9 million bottles of water (one bottle per day) and
- 27 million cups of coffee and tea; and
- At one bottle of beer each and one coca cola each per day, 18 million beverages will be consumed.





# TOURISM AS A SYSTEM

- Add in all the other consumables that are needed, such as:
  - electricity consumption and light bulbs;
  - furniture to sit on and sleep on;
  - soap for showers and laundry;
  - bed linen, table linen, curtains, and lounge fabrics;
  - pots and pans, cups and plates and knives and forks;
  - tennis balls; swimming goggles; golf buggies; beach umbrellas;
  - etcetera, and -
- the myth of tourism being 'just a service industry that doesn't produce anything' is completely exploded.
- Thus, when we look at tourism as a tool for poverty alleviation we find that we can look well beyond the front line sector to a multiplicity of opportunities ....










**The challenge for Cambodia is to do the same for its *"2006-2010 National Socio-Economic Strategy"* and apply tourism as a system across all sectors, where it can make a contribution to many national poverty alleviation objectives.**







# សហគមន៍ទេសចរណ៍ ៖ គោលការណ៍ បញ្ហា និងដំណើរការ



# តើទេសចរណ៍បែបសហគមន៍ជាអ្វី?



- គឺជាប្រភេទទេសចរណ៍ដែលគ្រប់គ្រង និងរៀបចំដោយសហគមន៍ និងសម្រាប់សហគមន៍
- សហគមន៍យកចិត្តទុកដាក់លើធនធានរបស់ពួកគេ និងទាញយកប្រាក់ ចំណូលពីទេសចរណ៍ ដើម្បីធ្វើឱ្យជីវភាពមានភាពប្រសើរឡើង
- វាទាក់ទងជាមួយនឹង ការអភិរក្ស ការផ្តល់អំណាចឱ្យសហគមន៍មូលដ្ឋាន ជំនួញ និងការអភិវឌ្ឍសហគមន៍



# តើនរណាជាសហគមន៍?

- សហគមន៍ជាក្រុមមនុស្ស រស់នៅក្នុងតំបន់ភូមិសាស្ត្រតែមួយ ហើយស្ថិតនៅក្នុងក្រុមតែមួយដូចគ្នា
- ពួកគេអាចមានទំនាក់ទំនងសាច់ឈាម តាមអាពាហ៍ពិពាហ៍ សាសនា បក្សនយោបាយ ឬថ្នាក់
- ផ្ទុយទៅវិញ គេមិនត្រូវគិតថាសហគមន៍ជាក្រុមមួយដូចគ្នានោះទេ
- ពួកគេអាចមានភាពផ្សេងគ្នាពីអ្នកគ្មានដី អ្នកមានដី អ្នកក្រ អ្នកមាន អ្នកចំណូល ថ្មី និងចាស់



## ទេសចរណ៍បែបសហគមន៍ និងការអភិវឌ្ឍសហគមន៍

- ទេសចរណ៍បែបសហគមន៍ជាឧបករណ៍សម្រាប់សហគមន៍ធ្វើការអភិរក្សធនធានធម្មជាតិ និងវប្បធម៌
- ដូច្នេះ យើងគួរអនុវត្តទស្សនៈរួម (សេដ្ឋកិច្ច សង្គម វប្បធម៌ បរិស្ថាន និងនយោបាយ)



## ទិដ្ឋភាព ៥ នៃការអភិវឌ្ឍសហគមន៍

១. សេដ្ឋកិច្ច

២. សង្គម

៣. វប្បធម៌

៤. បរិស្ថាន

៥. នយោបាយ



តើទេសចរណ៍បែបសហគមន៍មានឥទ្ធិពលលើផ្នែកទាំង ៥ នេះយ៉ាងដូចម្តេច?

# ផ្នែកសេដ្ឋកិច្ច

- បង្កើតមូលនិធិសម្រាប់អភិវឌ្ឍសហគមន៍
- បង្កើតការងារក្នុងវិស័យទេសចរណ៍
- បង្កើតប្រាក់ចំណូលសម្រាប់សហគមន៍មូលដ្ឋាន





# ផ្នែកសង្គម

- គុណភាពជីវិតប្រសើរឡើង
- ផ្សព្វផ្សាយមោទនភាពរបស់សហគមន៍
- បែងចែកតួនាទីសមស្របរវាងស្ត្រី និងបុរស ចាស់ និងក្មេង
- បង្កើតអង្គការគ្រប់គ្រងសហគមន៍



## ផ្នែកវប្បធម៌

- លើកទឹកចិត្តឱ្យមានការគោរពចំពោះវប្បធម៌ផ្សេងៗគ្នា
- ធ្វើឱ្យមានបម្លាស់ប្តូរវប្បធម៌
- បង្កប់នូវការអភិវឌ្ឍវប្បធម៌មូលដ្ឋាន



## ផ្នែកបរិស្ថាន

- បង្កើតការយល់ដឹងពីតម្រូវការអភិរក្ស
- គ្រប់គ្រងការបោះចោលកាកសំណល់
- បង្កើតមោទនភាពមូលដ្ឋាន



## ផែ្នកនយោបាយ

- លើកទឹកចិត្តឱ្យមានការចូលរួមពីសហគមន៍មូលដ្ឋាន
- ផ្តល់អំណាចឱ្យប្រជាជនមូលដ្ឋាន
- ធានាឱ្យមានសិទ្ធិក្នុងការគ្រប់គ្រងធនធានធម្មជាតិ



## គោលការណ៍ ១០ យ៉ាងនៃសហគមន៍ទេសចរណ៍

១.ទទួលស្គាល់ គាំទ្រ និងផ្សព្វផ្សាយពីភាពជាម្ចាស់របស់សហគមន៍លើវិស័យទេសចរណ៍

២. បញ្ចូលទំនាក់ទំនងរបស់សមាជិកសហគមន៍នៅគ្រប់ផ្នែកតាំងពីចាប់ផ្តើមដំបូង

៣. ផ្សព្វផ្សាយមោទនភាពរបស់សហគមន៍

៤. ធ្វើឱ្យគុណភាពជីវិតមានភាពប្រសើរឡើង

៥. ធានាបរិស្ថានឱ្យមាននិរន្តរភាព

៦. ថែរក្សាវប្បធម៌មូលដ្ឋាន



## គោលការណ៍ ១០ យ៉ាងនៃសហគមន៍ទេសចរណ៍

៧. សិក្សាវប្បធម៌ពីគ្នាទៅវិញទៅមក

៨. ឱ្យតម្លៃលើភាពផ្សេងៗគ្នានៃវប្បធម៌ និងភាពថ្លៃថ្នូររបស់មនុស្ស

៩. ការបែងចែងផលប្រយោជន៍ដោយសមធម៌

១០. រួមចំណែកក្នុងការអភិវឌ្ឍសហគមន៍



## បញ្ហារបស់សហគមន៍ទេសចរណ៍

- ការចូលរួម
- សមភាពភេទ
- ការសម្រេចចិត្ត
- កង្វះមូលនិធិ
- កង្វះច្បាប់គាំទ្រ
- សមត្ថភាពគ្រប់គ្រងមូលដ្ឋាននៅខ្សោយ
- ការបែងចែកផលប្រយោជន៍
- ជំលោះ ភាពច្រណែន និងការបែងចែក



## ១០ ជំហានក្នុងការបង្កើតសហគមន៍ទេសចរណ៍

១. ជ្រើសរើសតំបន់

២. សិក្សាលទ្ធភាពធ្វើបាន

៣. បង្កើតចក្ខុវិស័យ និងគោលបំណង

៤. បង្កើតផែនការចូលរួម

៥. បង្កើតទិសដៅសម្រាប់ការគ្រប់គ្រងស្ថាប័ន

៦. បង្កើតកម្មវិធីទេសចរណ៍



## ១០ ជំហានក្នុងការបង្កើតសហគមន៍ទេសចរណ៍

៧. បណ្តុះបណ្តាលមគ្គុទេសក៍នាំផ្លូវ

៨. បង្កើតផែនការសិក្សាទីផ្សារ

៩. សាកល្បងកម្មវិធីដំណើរទេសចរណ៍

១០. ត្រួតពិនិត្យ
និងវាយតម្លៃដំណើរការ



# ការជ្រើសរើសតំបន់

# សំរាប់សហគមន៍ទេសចរណ៍

## ការជ្រើសរើសតំបន់

- សក្តានុពលរបស់សហគមន៍?
- សក្តានុពលទីផ្សារទេសចរណ៍បែបសហគមន៍?
- គោលនយោបាយរដ្ឋាភិបាល និងតួនាទីរបស់រដ្ឋាភិបាលមូលដ្ឋានក្នុងការគាំទ្រទេសចរណ៍បែបសហគមន៍?
- ការសម្របសម្រួល និងផ្តល់មូលនិធិ?

## ការវាយតម្លៃសក្តានុពលរបស់សហគមន៍

- ចរិតលក្ខណៈសហគមន៍ច្បាស់លាស់
- ភាពទាក់ទាញធម្មជាតិ និងវប្បធម៌
- ស្ថាប័នសហគមន៍
- ជំលោះផ្ទៃកខាងក្នុង
- ផលិតផល និងធនធាន
- បញ្ហាគ្រោះទុរភិក្ស និងគ្រោះថ្នាក់

- ការយល់ដឹងពីទំនាក់ទំនងរវាងសហគមន៍មូលដ្ឋាន ការអភិរក្ស និងបម្រើបម្រាស់ធនធាន
  - តើសកម្មភាពអ្វីដែលគាំទ្រ និងប៉ះពាល់បរិស្ថាន?
  - អេកូទេសចរណ៍គឺជាជម្រើសមួយ ដើម្បីផ្លាស់ប្តូរឥរិយាបថ និងសកម្មភាព ⟶ ថែរក្សាផលប្រយោជន៍?
  - ការអភិវឌ្ឍការចិញ្ចឹមជីវិត ⟷ ជម្រើសអេកូទេសចរណ៍?

- ភាពទាក់ទាញធម្មជាតិ និងវប្បធម៌ ⟶ ពិនិត្យលើលក្ខណៈសក្តានុពលធម្មជាតិ និងវប្បធម៌ថាជាវត្ថុទាក់ទាញទេសចរ
- ស្ថាប័នសហគមន៍ ⟶ ពិនិត្យលើតួនាទីផ្លូវការ និងក្រៅផ្លូវការរបស់ក្រុមក្នុងសហគមន៍
- ជំលោះផ្ទៃកខាងក្នុង : ប្រភេទជំលោះ? ដំណោះស្រាយ?

## ការវាយតម្លៃសក្តានុពលទីផ្សារទេសចរណ៍បែបសហគមន៍

- ចំណាប់អារម្មណ៍របស់ទេសចរ និងកត្តាជំរុញ?
  - ➢ លក្ខណៈរូប : តម្រូវការការកំសាន្ត សុខភាព លំហែ?
  - ➢ វប្បធម៌ : រៀនវប្បធម៌ដទៃ
  - ➢ សង្គម : ជួបជាមួយមនុស្ស, ទៅសួរសុខទុក្ខញាតិមិត្ត
  - ➢ ស្មារតី :ធម្មយាត្រា, សាសនា
  - ➢ គេចចេញពីជីវិតប្រចាំថ្ងៃ

---

- យល់ដឹងពីតម្រូវការទីផ្សារ/ការរំពឹងគិតរបស់អតិថិជន ←
  តើត្រូវផ្តល់ ផលិតផល និងសេវាកម្មយ៉ាងដូចម្តេច?
- យល់ពីគំរូ ទម្រង់ និងចំណាប់អារម្មណ៍របស់ទេសចរដែលមានស្រាប់
  នៅក្នុងតំបន់

## ការវាយតម្លៃសក្តានុពលទីផ្សារទេសចរណ៍បែបសហគមន៍(ត)

ចំនុចត្រូវវិភាគផ្សេងទៀតមាន :

- និន្នាការទេសចរណ៍ពិភពលោក
- ចំណែកទីផ្សាររបស់ប្រទេសក្នុងទេសចរណ៍ពិភពលោក
- ចំនួនទេសចរជាតិ
- គោលបំណងនៃការទស្សនា
- ការរៀបចំការធ្វើដំណើរ
- អាយុ
- ការងារ
- រយៈពេលស្នាក់នៅជាមធ្យម
- ការចំនាយជាមធ្យម

## គោលនយោបាយរដ្ឋាភិបាលនិងតួនាទីរបស់រដ្ឋាភិបាលមូលដ្ឋានក្នុងការគាំទ្រទេសចរណ៍បែបសហគមន៍

- ផែនការរដ្ឋាភិបាលដែលទាក់ទងក្នុងការអភិវឌ្ឍវិស័យទេសចរណ៍ :
  - កម្រិតជាតិ
  - កម្រិតតំបន់
  - តួនាទីរបស់អជ្ញាធរមូលដ្ឋាន

# សហគមន៍ទេសចរណ៍

# ការសិក្សាពីលទ្ធភាពអាចធ្វើបាន

## ដំណាក់កាលអនុវត្តការសិក្សាពីលទ្ធភាពអាចធ្វើបាន

- គោលបំណងសហគមន៍ និងជំរុញការអភិវឌ្ឍទេសចរណ៍បែបសហគមន៍
- ការយល់ដឹងពីទេសចរណ៍បែបសហគមន៍
- ផលប៉ះពាល់ទេសចរណ៍វិជ្ជមាន និងអវិជ្ជមាន
- ចំនុចខ្លាំង និងចំនុចខ្សោយរបស់សហគមន៍
- វិភាគលើការចូលរួម

## ការយល់ដឹងពីសហគមន៍ : ចំនុចដែលគួរវិភាគ

- រចនាសម្ព័ន្ធគោលនយោបាយ និងរដ្ឋបាល
- លក្ខណៈប្រជាសាស្ត្រ និងអត្រាប្រជាជន
- សកម្មភាពសេដ្ឋកិច្ច
- ស្ថាប័ន តួនាទី និងសកម្មភាព
- ទម្រង់ដឹកនាំ និងឥទិពលរបស់វា
- វប្បធម៌ និងប្រពៃណី
- ធនធានធម្មជាតិ
- សុខភាព និងអនាម័យ
- ការអប់រំ
- បញ្ហាគួរគិត

## ចំនុចត្រូវត្រួតពិនិត្យ

- ចំណាប់អារម្មណ៍ និងការចូលរួមរបស់សហគមន៍ក្នុងវិស័យទេសចរណ៍?
- ភាពទាក់ទាញទេសចរសក្តានុពល?
- គ្រោះថ្នាក់នៃផលប៉ះពាល់-ត្រូវតែគ្រប់គ្រង និងត្រួតពិនិត្យ
- ការប្តេជ្ញារបស់ស្ថាប័នផ្តល់ជំនួយ

## គោលបំណងសហគមន៍ និងជំរុញការអភិវឌ្ឍទេសចរណ៍បែបសហគមន៍

- ទេសចរណ៍បែបសហគមន៍ ⟶ បង្កើតប្រាក់ចំណូល?
- ទេសចរណ៍បែបសហគមន៍ ⟶ អភិរក្ស និងធ្វើឱ្យធនធានធម្មជាតិ និងវប្បធម៌ល្អឡើងវិញ?
- ទេសចរណ៍បែបសហគមន៍ ⟶ ជំរុញការចូលរួមរបស់សហគមន៍?

## ការយល់ដឹងពីទេសចរណ៍បែបសហគមន៍

- សំនួរគន្លឹះ
  - ប្រជាជនមូលដ្ឋានយល់ពី ទេសចរណ៍បែបសហគមន៍ទេ?
  - សហគមន៍នឹងផ្លាស់ប្តូរបន្ទាប់ពីបង្កើតទេសចរណ៍បែបសហគមន៍?
  - កត្តាអ្វីធ្វើឱ្យទេសចរណ៍បែបសហគមន៍ទទួលបានជោគជ័យ?
  - តើអ្វីជាឧបសគ្គ?



## ផលប៉ះពាល់ទេសចរណ៍វិជ្ជមាន និងអវិជ្ជមាន

- បរិស្ថាន
- វប្បធម៌
- សង្គម
- សេដ្ឋកិច្ច
- ការចូលរួម
- ចរិតលក្ខណៈរបស់ទេសចរ

## សំនួរសំខាន់ៗសំរាប់ការវាយតំលៃ

**ផលប៉ះពាល់វិជ្ជមាន :**

- តើអ្វីផលប៉ះពាល់វិជ្ជមាននៃវិស័យទេសចរណ៍?
- តើនរណាទទួលផលប្រយោជន៍ពីទេសចរណ៍?
- តើមានអ្វីកើតឡើងទេបន្ទាប់ពីគេទទួលបានផលប្រយោជន៍ទាំងនោះ?

**ផលប៉ះពាល់អវិជ្ជមាន :**

- តើអ្វីជាផលប៉ះពាល់អវិជ្ជមាន?
- តើនរណាទទួលរងឥទិពលពីផលប៉ះពាល់នោះ?
- តើផលប៉ះពាល់នោះបំផ្លាញសហគមន៍យ៉ាងដូចម្តេច?

## បញ្ហាត្រូវសិក្សា

- បម្រែបម្រួលសហគមន៍ពីមុន និងក្រោយពេលអភិវឌ្ឍទេសចរណ៍
- ផលប៉ះពាល់វិជ្ជមាន និងអវិជ្ជមាន
- ការចូលរួមរបស់ប្រជាជនមូលដ្ឋាន
- ការចែកចាយផលប្រយោជន៍
- ការគ្រប់គ្រងស្ថាប័នសហគមន៍
- ការសិក្សាទីផ្សារ

## ចំនុចខ្លាំង និងចំនុចខ្សោយរបស់សហគមន៍

- ធនធានធម្មជាតិ
- វប្បធម៌ និងរចនាបថជីវិត
- ឧត្តមគតិមូលដ្ឋាន
- ស្ថាប័នសហគមន៍
- មូលនិធិ និងហិរញ្ញវត្ថុរបស់សហគមន៍
- ហេដ្ឋារចនាសម្ព័ន
- ទេសចរ
- ការប្រកួតប្រជែង
- រដ្ឋាភិបាលមូលដ្ឋាន/ស្ថាប័នសម្របសម្រួល

## តើត្រូវប្រមូលពត៌មានទាំងនោះដោយវិធីណា?

- ផែនទីធនធានសហគមន៍ : ព្រំប្រទល់សហគមន៍ ធនធានធម្មជាតិ ហេដ្ឋារចនាសម្ព័ន ( ផ្លូវ ទឹក...) ផ្លូវធ្វើដំណើរទេសចរណ៍
- ប្រតិទិនតាមរដូវ : សកម្មភាពមូលដ្ឋាន ( សកម្មភាពកសិកម្ម និងមិនមែនកសិកម្ម...)
- ការវិភាគតាមបន្ទាត់និន្នាការ  សង្គម បរិស្ថាន វប្បធម៌ សេដ្ឋកិច្ច របស់សហគមន៍



# ការសិក្សាទីផ្សារទេសចរណ៍បែបសហគមន៍

## តើការសិក្សាទីផ្សារជាអ្វី?

- ការសិក្សាទីផ្សារគឺជាការផ្គូរផ្គងការផ្គត់ផ្គង់ (ផលិតផល) ជាមួយតម្រូវការ (ទេសចរ)
- គោលបំណងរបស់ការសិក្សាទីផ្សារគឺបង្កើនការលក់
- ប៉ុន្តែ ជៀសវាងផលប៉ះពាល់អវិជ្ជមាន ដោយផ្តល់នូវពតិមានត្រឹមត្រូវមុនពេលជាវផលិតផល

## បញ្ហាដែលត្រូវគិត នៅពេលធ្វើការសិក្សាទីផ្សារទេសចរណ៍បែបសហគមន៍

១. ផលិតផល

២. កម្មវិធី

៣. តម្លៃ

៤. កញ្ចប់

៥. មនុស្ស និងទេសចរ

៦. ទីកន្លែង : ប្រភពទេសចរ

៧. ការផ្សព្វផ្សាយ

៨. ភាពជាដៃគូ

## ផលិតផល/ធនធានទេសចរណ៍បែបសហគមន៍

- ធនធាន/ព្រឹត្តិការណ៍ធម្មជាតិ
- ធនធាន/ព្រឹត្តិការណ៍វប្បធម៌
- ធនធានសង្គម
- ធនធានវប្បធម៌
- ធនធានមនុស្ស
- ហេដ្ឋារចនាសម្ព័ន្ធ
- សេវាកម្ម

## កម្មវិធី/ដំណើរទេសចរណ៍

- តើទេសចរអាចធ្វើ និងមើលអ្វីខ្លះនៅក្នុងសហគមន៍?
- តើគេអាចគ្រប់គ្រងវាយ៉ាងដូចម្តេច?
- តើទេសចរធ្វើដំណើរតាមផ្លូវអ្វី?
- តើពួកគេធ្វើដំណើរយៈពេលប៉ុន្មានថ្ងៃ?

## តម្លៃ

- បង្កើតបទដ្ឋានតម្លៃ
- តម្លៃប្រកួតប្រជែង
- តម្លៃសមស្រប
- តម្លៃពិសេស
- តម្លៃលក់ផ្ទាល់ និងមិនផ្ទាល់
- ត្រូវឱ្យទេសចរដឹងពីវិធីដែលគេចំណាយប្រាក់ចំណូល

## កញ្ចប់ : តម្លៃ និងកម្មវិធី

- តម្លៃកញ្ចប់ទេសចរណ៍គួររួមមានគ្រប់សកម្មភាព និងសេវាកម្ម :

  - ការដឹកជញ្ជូន
  - ការស្នាក់នៅ
  - អាហារ
  - មគ្គុទេសក៍
  - តម្លៃចូលទស្សនា

## មនុស្ស/ទេសចរ

- តើនរណាជាទេសចរ?

  - ខ្មែរ/បរទេស
  - តាមរយៈក្រុមហ៊ុន/ដោយខ្លួនគេផ្ទាល់
  - ក្រុមមានទំហំប៉ុណ្ណា?
  - ពួកគេមានអាយុប៉ុន្មាន?
  - ពួកគេមានចំណាប់អារម្មណ៍អ្វី?
  - ទេសចរប្រភេទណា? ស្វែងរកបទពិសោធន៍ថ្មី ការអប់រំ ឬភាពសុខស្រួល?

## តើនរណាទៅទស្សនាសហគមន៍?

- អ្នកប្រមូល
- អ្នកកំសាន្ត
- អ្នកយកចេញធនធាន
- អ្នកអភិវឌ្ឍន៍
- តំណាងស្ថាប័នមិនមែនរដ្ឋាភិបាល
- ក្រុមសាសនា
- អ្នកជំនួញ
- អ្នកស្រាវជ្រាវ
- អ្នកថតរូប, អ្នកកាសែត អ្នកផលិតខ្សែភាពយន្ត
- និស្សិត

## ទីកន្លែង : ប្រភពទេសចរ

- តើប្រទេសណាជាប្រទេសបង្កើតទេសចរ?
- តើនរណាជាដៃគូប្រកួតប្រជែង

## ការផ្សព្វផ្សាយ

- បណ្តាញចូលទីផ្សារ : ប្រព័ន្ធពត៌មាន, រដ្ឋាភិបាល ឬពីមាត់មួយទៅមាត់មួយ
- ប្រព័ន្ធផ្សព្វផ្សាយ : សៀវភៅផ្សព្វផ្សាយ, វីដេអូ, ប័ណ្ណប្រកាស ឬអ៊ិនធើណែត

## ភាពជាដៃគូ

- សណ្ឋាគារ
- ក្រុមហ៊ុនទេសចរណ៍
- រដ្ឋាភិបាល
- ស្ថាប័នមិនមែនរដ្ឋាភិបាល
- ទេសចរណ៍បែបសហគមន៍ផ្សេងៗទៀត

# ការត្រួតពិនិត្យ និងការវាយតម្លៃ

**តើការត្រួតពិនិត្យជាអ្វី?**

- ការត្រួតពិនិត្យ គឺជាដំណើរការពិនិត្យមើលសកម្មភាពទៅមុខ ដោយប្រមូល និងវិភាគលើពត៌មានដែលទាក់ទង ដើម្បីកំណត់ថាតើគម្រោងការត្រូវតាមគោលបំណងដែលចង់បានដែរឬទេ។

**តើការវាយតម្លៃជាអ្វី?**

- ការវាយតម្លៃកើតឡើងនៅក្នុងចន្លោះពេលមួយទៀងទាត់ ដើម្បីកំណត់ថាតើគម្រោងការណ៍បានសម្រេចតាមគោលបំណងដោយមានប្រសិទ្ធិភាពទេ និងថាតើគម្រោងការណ៍អាចនាំមកនូវលទ្ធផលប្រកបដោយនិរន្តរភាពទេ។

## តើគេត្រួវតាមដានត្រួតពិនិត្យលើអ្វី?

១. បរិស្ថាន

២. សេដ្ឋកិច្ច

៣. វប្បធម៌

៤. ប្រព័ន្ធសង្គម

៥. ការចូលរួមរបស់សហគមន៍

៦. ការពេញចិត្តរបស់ភ្ញៀវទេសចរ

## តើត្រួវតាមដានត្រួតពិនិត្យយ៉ាងដូចម្តេច?

- បន្ទាត់និន្នាការ
- ដ្យាក្រាម Venn
- ទម្រង់ផ្តល់មតិយោបល់របស់ភ្ញៀវទេសចរ
- ទម្រង់ផ្តល់មតិយោបល់របស់សហគមន៍
- ការសង្កេត

## សន្ទស្សន៍ (Indicator)

សន្ទស្សន៍ដែលល្អត្រូវ :

១. បរិមាណ និងគុណភាព

២. ជាក់លាក់ ឬអាចកំណត់បាន

៣. អាចវាស់បាន

៤. សមស្របតាមទំហំគម្រោង ពេលវេលា និងធនធាន

## ការតាមដានត្រួតពិនិត្យលើគោលបំណងរបស់ទេសចរណ៍បែបសហគមន៍

| គោលបំណង | សន្ទស្សន៍ | ឧបករណ៍ | លទ្ធផល |
|---|---|---|---|
| បង្កើតការផ្តួចផ្តើមគំនិតមូលដ្ឋានក្នុងការអភិរក្សធនធានធម្មជាតិ | • កើន/ថយ គុណភាពនៃសកម្មភាពអភិរក្សមូលដ្ឋាន | • ការប្រជុំ<br>• ការអភិរក្ស | |
| ថែរក្សា និងធ្វើឱ្យវប្បធម៌ប្រសើរឡើង | • កើន/ថយ ស្នេហភាពវប្បធម៌<br>• ពង្រីកគុណភាពសកម្មភាព | • ការសង្កេត<br>• ការសំភាស | |

| | | | |
|---|---|---|---|
| បង្កើតប្រាក់ចំណូល និងបង្កើនគុណភាពជីវិត | • កើន/ថយប្រាក់ ចំណូល ផលប៉ះពាល់ផ្នែកបរិស្ថាន និងវប្បធម៌ ការចែកចាយប្រាក់ចំណូលពីវិស័យទេសចរណ៍ចំពោះការអភិវឌ្ឍសហគមន៍ | • ការស្ទាបស្ទង់ទិន្នន័យតាមបន្ទាត់មូលដ្ឋាន • ការស្ទាបស្ទង់ពីប្រាក់ចំណូល | |
| លើកទឹកចិត្តឱ្យមានការចូលរួមសង្គម | • កើន/ថយការប្រជុំ និងបណ្តុះបណ្តាល | បញ្ជីវត្តមាន | |

## ទម្រង់ផ្តល់មតិយោបល់របស់សហគមន៍

| ប្រធានបទ | ពេញចិត្ត | ធម្មតា | មិនពេញចិត្ត |
|---|---|---|---|
| បម្រែបម្រួលប្រាក់ចំណូល | | | |
| ឥរិយាបថទេសចរ | | | |
| ឥរិយាបថអ្នកមគ្គុទ្ទេសក៍ | | | |
| សាមគ្គីភាពសហគមន៍ | | | |
| វប្បធម៌មូលដ្ឋាន | | | |
| អាហារ និងសុខភាព | | | |
| ធនធានធម្មជាតិ | | | |
| របៀបរបបជីវិតមូលដ្ឋាន | | | |
| ការពេញចិត្តចំពោះគម្រោងទេសចរណ៍បែបសហគមន៍ | | | |

## ការត្រួតពិនិត្យផលប៉ះពាល់

| ប្រភេទផលប៉ះពាល់ | សន្ទស្សន៍ | ឧបករណ៍ | លទ្ធផល |
|---|---|---|---|
| បរិស្ថាន | កើន/ធ្លាក់ចុះ : ចំនួនពពួកសត្វ និង រុក្ខជាតិ, សំរាម, គុណភាពទឹក | • ការស្ទាបស្ទង់<br>• បន្ទាត់និន្នាការ | |
| វប្បធម៌ | កើន/ធ្លាក់ចុះ : កម្រិតធ្វើឱ្យវប្បធម៌ រស់រានឡើងវិញ ឥរិយាបថ និងពាក្យសំដី | • បន្ទាត់និន្នាការ | |
| សង្គម | កើន/ថយ ជម្លោះសង្គម | • បន្ទាត់និន្នាការ<br>• ដ្យាក្រាម Venn | |
| សេដ្ឋកិច្ច | កើន/ថយ ប្រភពប្រាក់ចំណូល | • តារាងប្រាក់ចំណូល<br>• ប្រតិទិនតាមរដូវ | |
| នយោបាយ | សមត្ថភាពចរចារជាមួយភាគីពាក់ព័ន្ធ | • ដ្យាក្រាម Venn | |

## ដំណើរការវាយតម្លៃ

១. សិក្សា និងវិភាគទិន្នន័យពីដំណើរការត្រួតពិនិត្យ

២. សិក្សាពីផលប៉ះពាល់សង្គម សេដ្ឋកិច្ច វប្បធម៌ បរិស្ថាន និងការចូលរួមរបស់សហគមន៍

៣. វាយតម្លៃលើភាពជោគជ័យនិង បរាជ័យ នៃគោលបំណងទេសចរណ៍បែបសហគមន៍

៤. វាយតម្លៃល័ក្ខខ័ណ្ឌប្រតិបត្តិការគម្រោង និងកត្តាចូលរួម

៥. វិភាគនិន្នាការដែលអាចមាន និងទិសដៅសម្រាប់ការអភិវឌ្ឍទេសចរណ៍បែបសហគមន៍នាពេលអនាគត

# ការចូលរួម និងការចងបណ្ដាញ

## ភាគីពាក់ព័ន្ធក្នុងទេសចរណ៍បែបសហគមន៍

១. សហគមន៍

២. ទេសចរ

៣. អង្គការមិនមែនរដ្ឋាភិបាល ឬម្ចាស់ជំនួយ

៤. ស្ថាប័នរដ្ឋាភិបាល

៥. ជំនួញទេសចរណ៍

៦. ស្ថាប័នអប់រំ

តើពួកគេត្រូវការអ្វី?

## គុណសម្បត្តិ និងគុណវិបត្តិនៃការសហការណ៍រវាងសហគមន៍ និងវិស័យឯកជន

| ភាគី | គុណសម្បត្តិ | គុណវិបត្តិ |
|---|---|---|
| សហគមន៍ | បង្កើនការសិក្សាទីផ្សារ, ការបណ្តាក់ទុន និងជំនាញ | ត្រូវតែចែករំលែកប្រាក់ចំណូល |
| វិស័យឯកជន | ទទួលបានកេរ្តិ៍ឈ្មោះល្អ | មិនអាចធ្វើការសម្រេចចិត្ត ដោយឯករាជ្យ |
| ទាំងពីរ | ចែករំលែកចំណេះដឹង បទពិសោធន៍ និងការធ្វើការជាមួយគ្នាដើម្បីទទួលបានភាពជោគជ័យ | -កិច្ចព្រមព្រៀងលើការចែកចាយផលប្រយោជន៍<br>- ចំណាយពេលនិងថាមពលឥតប្រយោជន៍<br>- គោលបំណងខុសគ្នា |

# កម្រិតនៃភាគីពាក់ព័ន្ធ

- ថ្នាក់សហគមន៍
- ថ្នាក់ខេត្ត
- ថ្នាក់ជាតិ
- ថ្នាក់អន្តរជាតិ

## ហេតុអ្វីត្រូវមានការចូលរួម?

- ចែកចាយពត៌មាន
- ផ្លាស់ប្តូរគំនិត និងបទពិសោធន៍
- ចែកចាយធនធាន
- ចែករំលែកទំនួលខុសត្រូវ
- ភាពជាដៃគូ
- ការចូលរួមសហការណ៍គ្នា
- ភាគីពាក់ព័ន្ធ
- ភាពជាម្ចាស់

## ដំណើរការចូលរួម

១.កំណត់តួនាទីនៃការចូលរួម

២. ផ្តល់អំណាច និងកសាងសមត្ថភាព

៣. ការចូលរួមនៅក្នុងដំណើរគម្រោង

៤. បង្កើតភាគីពាក់ព័ន្ធ

៥. ភ្ជាប់ផលប្រយោជន៍ ទៅនិងការអភិរក្ស

៦.បែងចែកផលប្រយោជន៍

៧.បញ្ចូលមេសហគមន៍

៨.ប្រើភ្នាក់ងារផ្លាស់ប្តូរ (សំខាន់)

៩.ស្វែងយល់លក្ខខណ្ឌតំបន់

១០.ត្រួតពិនិត្យ និងវាយតម្លៃ

## បណ្តាញ

- ការបង្កើតបណ្តាញគឺជាទម្រង់កិច្ចសហប្រតិបត្តិការ លើកិច្ចព្រមព្រៀង ដោយស្ម័គ្រចិត្ត នៅពេលដែលភាគីទាំងអស់មានការប្តេជ្ញាចិត្តតែមួយ និងអនុវត្តសកម្មភាពដោយឯករាជ្យ
- ការសម្របសម្រួល នឹងផ្តល់អំណាចឱ្យស្ថាប័នមួយៗ

## ការបង្កើតបណ្តាញ

- បណ្តាញរឹងមាំអាស្រ័យលើអន្តរកម្មរបស់ផ្នែកទាំងបី :

១. ស្ថាប័នទេសចរណ៍បែបសហគមន៍

២. បណ្តាញអន្តរអង្គការ

៣. បញ្ចុះបញ្ចូលរកធនធានរដ្ឋាភិបាល និងជំនួយ

## ស្ថាប័នទេសចរណ៍បែបសហគមន៍

- វាចាំបាច់អភិវឌ្ឍ ៖

១. គំនិតផ្តួចផ្តើម និងការយល់ដឹងពីអ្នកដឹកនាំ និងសមាជិក

២. ជំនាញវិភាគលើបុគ្គលិក ស្ថាប័នផ្នែកខាងក្នុង ឬភាគីផ្សេងៗទៀតដែលចូលរួម

៣. ជំនាញគ្រប់គ្រងទេសចរណ៍

**បណ្តាញអន្តរស្ថាប័ន**

- ធ្វើការប្រជុំជាទៀងទាត់
- បង្កើតការប្តេជ្ញាថ្មីដើម្បីសម្រេចគោលបំណងរួម
- រៀបចំបម្លាស់ប្តូរសកម្មភាព

**បញ្ចុះបញ្ចូលរកធនធានរដ្ឋាភិបាល និងជំនួយ**

បញ្ចុះបញ្ចូលរកការយល់ព្រម និងការទទួលស្គាល់តួនាទីរបស់សហគមន៍

- បញ្ចុះបញ្ចូលរកមូលនិធិរបស់រដ្ឋាភិបាល និងការគាំទ្របច្ចេកទេស
- បញ្ចុះបញ្ចូលរដ្ឋាភិបាលឱ្យពង្រឹងច្បាប់